# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

របាយការណ៍ហិរញ្ញវត្ថុ
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់
ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022
និង
របាយការណ៍របស់សវនករឯករាជ្យ

## ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## មាតិកា


| | | ទំព័រ |
|---|---|---|
| 1. | របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | 1 – 5 |
| 2. | របាយការណ៍របស់សវនករឯករាជ្យ | 6 – 9 |
| 3. | របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | 10 |
| 4. | របាយការណ៍លទ្ធផលលម្អិត | 11 |
| 5. | របាយការណ៍ស្តីពីបម្រែបម្រួលមូលធន | 12 – 13 |
| 6. | របាយការណ៍លំហូរទឹកប្រាក់ | 14 – 15 |
| 7. | កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | 16 – 61 |

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានសេចក្តីសោមនស្សរីករាយ សូមធ្វើការបង្ហាញជូននូវរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ហៅកាត់ថា ("ក្រុមហ៊ុន") សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺការផ្តល់នូវសេវាហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត និងមានឥទ្ធិពលដល់សហគមន៍ សហគ្រាសខ្នាតតូច និងមធ្យម និងកសិករ ជាពិសេសស្ត្រី ប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងការទទួលខុសត្រូវខ្ពស់។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 មានដូចខាងក្រោម៖

| | 2022 | | 2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ប្រាក់ចំណេញមុនដកពន្ធ | 205,943 | 841,689 | 341,252 | 1,388,213 |
| ចំណាយពន្ធលើប្រាក់ចំណេញ | (61,553) | (251,567) | (76,186) | (309,925) |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | 144,390 | 590,122 | 265,066 | 1,078,288 |

## ដើមទុន

ពុំមានការប្រែប្រួលរចនាសម្ព័ន្ធភាគហ៊ុន ក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ។ សូមមើលកំណត់សម្គាល់ 17 សម្រាប់ព័ត៌មានលម្អិត។

## ភាគលាភ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានការប្រកាស ឬបែងចែកភាគលាភឡើយ ហើយក្រុមប្រឹក្សាភិបាលក៏ពុំមានអនុសាសន៍ឲ្យមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 នោះដែរ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះឡើយ។


គ្រឹះស្ថានឯកជន
PRIVATE COMPANY
ផ្ទះលេខ១០១អា ផ្លូវ២៨៩ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក ភ្នំពេញ
ADDRESS # 101A, ST.289, BOEUNG KAK 1, TOUL KORK, PHNOM PENH
TEL: (+855) 89 666 014, 081 855 222
WEBSITE: WWW.CAMMA.COM.KH

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## ឥណទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានា ដើម្បីធ្វើឲ្យប្រាកដថានីតិវិធីពាក់ព័ន្ធជាមួយនឹងការលុបចោលឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យ ត្រូវបានយកមកអនុវត្ត ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់ឥណទានអាក្រក់ដែលបានដឹងថាមិនអាចទារបាន ត្រូវបានលុបចោល ហើយសំវិធានធនត្រូវបានប៉ាន់ស្មានសមស្របសម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីព្រឹត្តិការណ៍ណាមួយដែលអាចបណ្តាលឲ្យចំនួនទឹកប្រាក់នៃឥណទានអាក្រក់ដែលបានលុបចោល ឬចំនួនទឹកប្រាក់សំវិធានធនលើឥណទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះទេ។

## ទ្រព្យសកម្ម

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានា ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មរយៈពេលខ្លីទាំងអស់ក្រៅពីឥណទាន ដែលទំនងជាមិនអាចទទួលស្គាល់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាក្នុងតម្លៃរបស់វាដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបានបន្ថយនៅស្មើនឹងតម្លៃដែលគិតថានឹងអាចទទួលស្គាល់បានជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលអាចបណ្តាលឲ្យការកំណត់តម្លៃទ្រព្យសកម្មរយៈពេលខ្លីនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានភាពមិនត្រឹមត្រូវនោះទេ។

## វិធីសាស្រ្តកំណត់តម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ហើយនឹងធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្រ្តដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ គឺពុំមាន៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទហិរញ្ញវត្ថុមក ក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុនឡើយ។

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## បំណុលយថាហេតុ និងបំណុលផ្សេងៗ (ត)

ក្រុមប្រឹក្សាភិបាលមានមតិថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងទៀតរបស់ក្រុមហ៊ុនដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងរយៈពេល 12ខែ បន្ទាប់ពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុ ដែលនឹងធ្វើឲ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល នៅក្នុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន៖

| | |
|---|---|
| លោកស្រី ឱត នីតា | ប្រធានក្រុមប្រឹក្សាភិបាល (តែងតាំងនៅថ្ងៃទី1 ខែកុម្ភៈ ឆ្នាំ2023) (*) |
| លោក ធន់ វឌ្ឍនា | ប្រធានក្រុមប្រឹក្សាភិបាល (លាលែងនៅថ្ងៃទី1 ខែកុម្ភៈ ឆ្នាំ2023) |
| លោក ខូវ សូវៀត | អភិបាល |
| លោកស្រី យូ បូរី | អភិបាលឯករាជ្យ |

(*) គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមហ៊ុនកំពុងរៀបចំធ្វើវិសោធនកម្មលើអនុស្សរណៈ និងលក្ខន្តិកៈក្រុមហ៊ុន ដើម្បីទទួលការអនុម័តពី ធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម។

## ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាលមានមតិថា លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទហិរញ្ញវត្ថុ ដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឲ្យប៉ះពាល់ជាសារវន្តដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងកាលបរិច្ឆេទហិរញ្ញវត្ថុ ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

## ភាគកម្មរបស់ក្រុមប្រឹក្សាភិបាល

ពុំមានអភិបាលណាម្នាក់កាន់កាប់ ឬមានការទាក់ទិននៅក្នុងភាគហ៊ុនរបស់ក្រុមហ៊ុនដោយផ្ទាល់ ឬដោយប្រយោលនៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ។

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនាចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានកិច្ចព្រមព្រៀងណាមួយដែលក្រុមហ៊ុនជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះបានផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ឲ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយនៃការទិញភាគហ៊ុននោះឡើយ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមុន ពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ ដែលបានរួមបញ្ចូលនៅក្នុងបរិលាភសរុបទទួលបាន ឬដល់កំណត់ទទួលបានដោយក្រុមប្រឹក្សាភិបាល ដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬដោយសាជីវកម្មពាក់ព័ន្ធណាមួយ ជាមួយនឹងក្រុមហ៊ុនណាមួយ ដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិកនៃក្រុមហ៊ុននោះ ឬក៏ជាមួយក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះមានភាគកម្មផ្នែកហិរញ្ញវត្ថុជាសារវន្តនោះទេ លើកលែងតែអ្វីដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ជាសារវន្តបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

- អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព
- អនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះ គឺត្រូវតែបង្ហាញ ពន្យល់ និងកំណត់បរិមាណឲ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីបង្ហាញនូវភាពពិត និងត្រឹមត្រូវ
- ត្រួតពិនិត្យប្រព័ន្ធដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព
- វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ និង
- ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចដែលមានសារៈសំខាន់ទាំងអស់ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថា កិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា ក្រុមប្រឹក្សាភិបាលបានអនុវត្តនូវរាល់តម្រូវការ ដូចមានរាយការណ៍ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងកំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយដូចដែលបានបង្ហាញនៅទំព័រទី10 ដល់ទី61 ថាបានបង្ហាញនូវភាពត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់ សហគ្រាសធុនតូច និងមធ្យម។

*ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាលដោយយោងលើការអនុម័តរបស់ក្រុមប្រឹក្សាភិបាល៖*

ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត CAMMA MICROFINANCE LIMITED

| | |
|---|---|
| លោកស្រី ឌិត នីតា | លោក លី ឈាង |
| *ប្រធានក្រុមប្រឹក្សាភិបាល* | *អគ្គនាយកប្រតិបត្តិស្តីទី* |

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី19 ខែមេសា ឆ្នាំ2023



គ្រឹះស្ថានឯកជន
PRIVATE COMPANY
ផ្ទះលេខ១០១អា ផ្លូវ២៨៩ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក ភ្នំពេញ
ADDRESS # 101A, ST.289, BOEUNG KAK 1, TOUL KORK, PHNOM PENH
TEL: (+855) 89 666 014, 081 855 222
WEBSITE: WWW.CAMMA.COM.KH

KPMG

KPMG Cambodia Ltd
GIA Tower, Sopheak Mongkul Street, Phum 14
Sangkat Tonle Bassac, Khan Chamkar Mon
Phnom Penh, Cambodia
+855 (17) 666 537 / +855 (81) 533 999 | kpmg.com.kh

# របាយការណ៍របស់សវនករឯករាជ្យ

## ជូនចំពោះភាគទុនិករបស់
## ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

### *មតិសវនកម្ម*

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ហៅកាត់ថា ("ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 របាយការណ៍លទ្ធផលលម្អិត របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ ដែលរួមមាន គោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗទៀត ដូចបានបង្ហាញនៅទំព័រទី10 ដល់ទី61 (ដែលហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុ")។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុ បានបង្ហាញនូវភាពត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម។

### *មូលដ្ឋាននៃមតិសវនកម្ម*

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដាទាំងនោះ ត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពី *ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ* ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំ មានភាពឯករាជ្យពីក្រុមហ៊ុនដោយស្របទៅតាមលក្ខខណ្ឌតម្រូវនៃក្រមសីលធម៌វិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវក្រមសីលធម៌វិជ្ជាជីវៈផ្សេងៗទៀតស្របតាមលក្ខខណ្ឌតម្រូវទាំងនេះ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបាន មានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

KPMG Cambodia Ltd., a Cambodian single member private limited company and a member firm of the KPMG global organization of independent member firms affiliated with KPMG International Limited, a private English company limited by guarantee. All rights reserved.

## *ព័ត៌មានផ្សេងៗ*

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗរួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ដូចបានបង្ហាញនៅទំព័រទី1 ដល់ទី5 និងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន ដែលរំពឹងថានឹងរួចរាល់ បន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ។ មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំមិនធ្វើការផ្តល់នូវអំណះអំណាងណាមួយទៅលើព័ត៌មានផ្សេងៗនេះទេ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុងឆ្គងជាសារវន្ត។

ប្រសិនបើការអានព័ត៌មានផ្សេងៗ ដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ អាចឲ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

## *បញ្ហាផ្សេងៗ*

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 ត្រូវបានធ្វើសវនកម្មដោយសវនករដទៃដែលបានបង្ហាញមតិត្រឹមត្រូវលើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះនៅថ្ងៃទី22 ខែមេសា ឆ្នាំ2022។

## *ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ចលើរបាយការណ៍ហិរញ្ញវត្ថុ*

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ហើយទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធ នូវបញ្ហាទាំងឡាយដែលទាក់ទិនទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀត ក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

KPMG

## *ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ*

គោលដៅរបស់យើងខ្ញុំ គឺទទួលបាននូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូល មិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករ ដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមួយដែលមានកម្រិតខ្ពស់ ប៉ុន្តែវាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុស អាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាមានលក្ខណៈសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងដោយឡែក ឬក៏រួមបញ្ចូលគ្នាអាចត្រូវបានរំពឹងទុកយ៉ាងសមហេតុផលថា នឹងជះឥទ្ធិពលដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយមក្នុងអំឡុងពេលធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការតាក់តែង និងអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យនៃការរកមិនឃើញនូវការបង្ហាញខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការបង្ហាញខុសដែលបណ្តាលមកពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំអាចទាក់ទិននឹងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ធ្វើការស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីតាក់តែងនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។
- ធ្វើការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលក្រុមហ៊ុនបានអនុវត្ត និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធនានា ដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។
- ធ្វើការសន្និដ្ឋានលើ ភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនប្រាកដប្រជាជាសារវន្តបានកើតមានឡើងពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចបង្កឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ក្រុមហ៊ុន ដើម្បីបន្តនិរន្តរភាពអាជីវកម្មដែរ ឬទេ។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថា មានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវទាញចំណាប់អារម្មណ៍ នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឲ្យក្រុមហ៊ុនបញ្ឈប់និរន្តរភាពនៃអាជីវកម្ម។

- ធ្វើការវាយតម្លៃលើការបង្ហាញ ទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដោយរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំ ផ្តល់ព័ត៌មាន ក្នុងចំណោមបញ្ហាផ្សេងៗ ជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ចស្តីពីវិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្ត ដោយរួមបញ្ចូលទាំងចំណុចខ្វះខាតជាសារវន្តក្នុងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា**

**ហ្គេក ធាវ**

*Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី19 ខែមេសា ឆ្នាំ2023

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
## នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

| | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 6 | 154,412 | 635,714 | 192,475 | 784,143 |
| សមតុល្យនៅធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុនានា | 7 | 741,756 | 3,053,809 | 630,550 | 2,568,861 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 8 | 282,032 | 1,161,126 | 328,394 | 1,337,877 |
| ឥណទានផ្តល់ដល់អតិថិជន | 9 | 23,327,329 | 96,038,613 | 15,203,043 | 61,937,197 |
| ទ្រព្យសកម្មផ្សេងៗ | 10 | 157,232 | 647,325 | 96,018 | 391,178 |
| ទ្រព្យ និងបរិក្ខារ | 11 | 149,293 | 614,640 | 75,845 | 308,993 |
| ទ្រព្យសកម្មអរូបី | 12 | 36,279 | 149,360 | - | - |
| **ទ្រព្យសកម្មសរុប** | | 24,848,333 | 102,300,587 | 16,526,325 | 67,328,249 |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| បំណុលពន្ធលើ ប្រាក់ចំណេញប្រចាំឆ្នាំ | 16(គ) | 75,773 | 311,957 | 10,108 | 41,180 |
| ប្រាក់កម្ចី | 13 | 15,341,077 | 63,159,214 | 9,477,204 | 38,610,129 |
| អនុបំណុល | 14 | 2,202,043 | 9,065,811 | - | - |
| បំណុលផ្សេងៗ | 15 | 155,066 | 638,407 | 70,632 | 287,755 |
| បំណុលពន្ធពន្យារ | 16(ឃ) | 1,193 | 4,912 | 39,590 | 161,290 |
| **បំណុលសរុប** | | 17,775,152 | 73,180,301 | 9,597,534 | 39,100,354 |
| **មូលធន** | | | | | |
| ដើមទុន | 17 | 5,593,000 | 22,372,000 | 5,593,000 | 22,372,000 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | 18 | 539,749 | 2,192,909 | 581,043 | 2,362,916 |
| ប្រាក់ចំណេញរក្សាទុក | | 940,432 | 3,840,400 | 754,748 | 3,080,271 |
| ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | - | 714,977 | - | 412,708 |
| **មូលធនសរុប** | | 7,073,181 | 29,120,286 | 6,928,791 | 28,227,895 |
| **បំណុល និងមូលធនសរុប** | | 24,848,333 | 102,300,587 | 16,526,325 | 67,328,249 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## របាយការណ៍លទ្ធផលលម្អិត
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

| | | 2022 | | 2021 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ចំណូលពីការប្រាក់ | 19 | 2,790,491 | 11,404,737 | 2,146,443 | 8,731,730 |
| ចំណាយលើការប្រាក់ | 10 | (800,626) | (3,272,158) | (535,366) | (2,177,869) |
| **ការប្រាក់សុទ្ធ** | | 1,989,865 | 8,132,579 | 1,611,077 | 6,553,861 |
| ចំណូលប្រតិបត្តិការផ្សេងៗ | 21 | 102,032 | 417,004 | 149,105 | 606,559 |
| **ចំណូលប្រតិបត្តិការសុទ្ធ** | | 2,091,897 | 8,549,583 | 1,760,182 | 7,160,420 |
| ការខាតបង់លើឱនភាពនៃតម្លៃសុទ្ធ លើទ្រព្យសកម្មហិរញ្ញវត្ថុ | 9 | (25,304) | (103,417) | (80,580) | (327,799) |
| ចំណាយលើបុគ្គលិក | 22 | (1,229,297) | (5,024,137) | (950,576) | (3,866,943) |
| ចំណាយរំលស់ | 23 | (43,702) | (178,610) | (42,661) | (173,545) |
| ចំណាយប្រតិបត្តិការផ្សេងៗ | 24 | (587,651) | (2,401,730) | (345,113) | (1,403,920) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | 205,943 | 841,689 | 341,252 | 1,388,213 |
| ចំណាយពន្ធលើប្រាក់ចំណេញ | 16(ខ) | (61,553) | (251,567) | (76,186) | (309,925) |
| **ប្រាក់ចំណេញសុទ្ធ សម្រាប់ការិយបរិច្ឆេទ** | | 144,390 | 590,122 | 265,066 | 1,078,288 |
| ***លទ្ធផលលម្អិតផ្សេងៗ*** | | | | | |
| *ធាតុដែលមិនត្រូវបានធ្វើចំណាត់ថ្នាក់ ឡើងវិញក្នុងចំណេញ ឬខាត* | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 302,269 | - | 284,837 |
| **លទ្ធផលលម្អិតសរុប សម្រាប់ការិយបរិច្ឆេទ** | | 144,390 | 892,391 | 265,066 | 1,363,125 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# ខេមរា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## របាយការណ៍ស្តីពីបម្រែបម្រួលមូលធន
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

| | ដើមទុន | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ប្រាក់ចំណេញរក្សាទុក | | ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ថ្ងៃទី1 ខែមករា ឆ្នាំ2022 | 5,593,000 | 22,372,000 | 581,043 | 2,362,916 | 754,748 | 3,080,271 | - | 412,708 | 6,928,791 | 28,227,895 |
| **ប្រតិបត្តិការជាមួយភាគទុនិកះ** | | | | | | | | | | |
| ផ្ទេរពីទុនបម្រុងតាមបទប្បញ្ញត្តិទៅ ប្រាក់ចំណេញរក្សាទុក (កំណត់សម្គាល់ 18) | - | - | (41,294) | (170,007) | 41,294 | 170,007 | - | - | - | - |
| | - | - | (41,294) | (170,007) | 41,294 | 170,007 | - | - | - | - |
| **លទ្ធផលលម្អិតសរុបះ** | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | 144,390 | 590,122 | - | - | 144,390 | 590,122 |
| លទ្ធផលលម្អិតផ្សេងៗ | - | - | - | - | - | - | - | 302,269 | - | 302,269 |
| | - | - | - | - | 144,390 | 590,122 | - | 302,269 | 144,390 | 892,391 |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | 5,593,000 | 22,372,000 | 539,749 | 2,192,909 | 940,432 | 3,840,400 | - | 714,977 | 7,073,181 | 29,120,286 |

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## របាយការណ៍ស្តីពីបម្រែបម្រួលមូលធន (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

| | ដើមទុន | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ប្រាក់ចំណេញរក្សាទុក | | ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ថ្ងៃទី1 ខែមករា ឆ្នាំ2021 | 3,593,000 | 14,372,000 | 357,594 | 1,452,585 | 713,131 | 2,912,314 | - | 127,871 | 4,663,725 | 18,864,770 |
| **ប្រតិបត្តិការជាមួយភាគទុនិកៈ** | | | | | | | | | | |
| ការបោះផ្សាយភាគហ៊ុនធម្មតា (កំណត់សម្គាល់ 17ក) | 2,000,000 | 8,000,000 | - | - | - | - | - | - | 2,000,000 | 8,000,000 |
| **ប្រតិបត្តិការផ្លាស់ប្តូរដោយផ្ទាល់ក្នុងមូលធនៈ** | | | | | | | | | | |
| ផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ (កំណត់សម្គាល់ 18) | - | - | 223,449 | 910,331 | (223,449) | (910,331) | - | - | - | - |
| | 2,000,000 | 8,000,000 | 223,449 | 910,331 | (223,449) | (910,331) | - | 127,871 | 2,000,000 | 8,000,000 |
| **លទ្ធផលលម្អិតសរុបៈ** | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | 265,066 | 1,078,288 | - | - | 265,066 | 1,078,288 |
| លទ្ធផលលម្អិតផ្សេងៗ | - | - | - | - | - | - | - | 284,837 | - | 284,837 |
| | - | - | - | - | 265,066 | 1,078,288 | - | 284,837 | 265,066 | 1,363,125 |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | 5,593,000 | 22,372,000 | 581,043 | 2,362,916 | 754,748 | 3,080,271 | - | 412,708 | 6,928,791 | 28,227,895 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## របាយការណ៍លំហូរទឹកប្រាក់
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

| | | 2022 | | 2021 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ប្រាក់ចំណេញសុទ្ធ សម្រាប់ការិយបរិច្ឆេទ | | 144,390 | 590,122 | 265,066 | 1,078,288 |
| *និយ័តភាពលើ៖* | | | | | |
| ការខាតបង់លើឱនភាពនៃតម្លៃ សុទ្ធលើទ្រព្យសកម្មហិរញ្ញវត្ថុ | 10 | 25,304 | 103,417 | 80,580 | 327,799 |
| រំលស់ | 23 | 43,702 | 178,610 | 42,661 | 173,545 |
| ចំណូលពីការប្រាក់ | | (2,790,491) | (11,404,737) | (2,146,443) | (8,731,730) |
| ចំណាយលើការប្រាក់ | | 800,626 | 3,272,158 | 535,366 | 2,177,869 |
| ចំណាយពន្ធលើប្រាក់ចំណេញ | | 61,553 | 251,567 | 76,186 | 309,925 |
| | | (1,714,916) | (7,008,863) | (1,146,584) | (4,664,304) |
| *បម្រែបម្រួលនូវ៖* | | | | | |
| ឥណទានផ្តល់ដល់អតិថិជន | | (8,059,198) | (32,937,942) | (2,176,603) | (8,854,421) |
| ទ្រព្យសកម្មផ្សេងៗ | | (61,219) | (250,202) | (19,636) | (79,879) |
| ប្រាក់តម្កល់តាមច្បាប់ | | - | - | (100,000) | (406,800) |
| បំណុលផ្សេងៗ | | 58,176 | 237,765 | (6,229) | (25,340) |
| សាច់ប្រាក់ប្រើប្រាស់ក្នុងប្រតិបត្តិការ | | (9,777,157) | (39,959,242) | (3,449,052) | (14,030,744) |
| ចំណូលពីការប្រាក់បានទទួល | | 2,700,104 | 11,035,325 | 2,158,521 | 8,780,863 |
| ចំណាយលើការប្រាក់បានបង់ | | (791,453) | (3,234,668) | (556,007) | (2,261,836) |
| ពន្ធលើប្រាក់ចំណេញបានបង់ | | (34,285) | (140,123) | (49,569) | (201,647) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពប្រតិបត្តិការ** | | (7,902,791) | (32,298,708) | (1,896,107) | (7,713,364) |

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## របាយការណ៍លំហូរទឹកប្រាក់ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

| | | 2022 | | 2021 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | 11 | (113,945) | (465,693) | (47,496) | (193,214) |
| ការទិញទ្រព្យសកម្មអរូបី | 12 | (39,484) | (161,371) | - | - |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | (153,429) | (627,064) | (47,496) | (193,214) |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | 13 | 16,477,548 | 67,343,739 | 8,807,064 | 35,827,136 |
| សាច់ប្រាក់ទទួលបានពីអនុបំណុល | 14 | 2,750,000 | 11,239,250 | - | - |
| ការទូទាត់សងប្រាក់កម្ចី | 13 | (10,594,547) | (43,299,914) | (8,345,450) | (33,949,291) |
| ការទូទាត់សងអនុបំណុល | 14 | (550,000) | (2,247,850) | - | - |
| សាច់ប្រាក់ទទួលបានពីការបោះផ្សាយភាគហ៊ុនធម្មតា | 17 | - | - | 2,000,000 | 8,136,000 |
| **សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពហិរញ្ញប្បទាន** | | 8,083,001 | 33,035,225 | 2,461,614 | 10,013,845 |
| **ការកើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | 26,781 | 109,453 | 518,011 | 2,107,267 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី1 ខែមករា** | | 871,769 | 3,551,587 | 353,758 | 1,430,951 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 38,290 | - | 13,369 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី31 ខែធ្នូ** | 6 | 898,550 | 3,699,330 | 871,769 | 3,551,587 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

កំណត់សម្គាល់ទាំងនេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ហើយគួរតែត្រូវបានអានជាមួយគ្នានឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ។

## 1. អំពីក្រុមហ៊ុន

ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ហៅកាត់ថា ("ក្រុមហ៊ុន") ត្រូវបានបង្កើតឡើងជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្មក្រោមបញ្ជីពាណិជ្ជកម្មលេខ Co.0700 KH/2010 ចុះថ្ងៃទី31 ខែមីនា ឆ្នាំ2010។ នៅថ្ងៃទី29 ខែកក្កដា ឆ្នាំ2010 ក្រុមហ៊ុនបានទទួលអាជ្ញាបណ្ណជាអចិន្ត្រៃយ៍ពីធនាគារជាតិនៃកម្ពុជា ដើម្បីប្រកបអាជីវកម្មជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

ចក្ខុវិស័យរបស់ក្រុមហ៊ុន គឺដើម្បីក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលអាចជឿទុកចិត្តមួយ ដែលផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយការរួបរួម និងច្នៃប្រឌិតទៅកាន់ប្រជាជនកម្ពុជា និងធានានូវអត្ថប្រយោជន៍សម្រាប់អតិថិជន បុគ្គលិក ភាគទុនិក និងសង្គមទាំងមូល។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺការផ្តល់នូវសេវាហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត និងមានឥទ្ធិពលដល់សហគមន៍ សហគ្រាសខ្នាតតូច និងមធ្យម និងកសិករ ជាពិសេសស្ត្រី ប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងការទទួលខុសត្រូវខ្ពស់។ ពុំមានការប្រែប្រួលលើសកម្មភាពអាជីវកម្មចម្បងក្នុងអំឡុងការិយបរិច្ឆេទនេះឡើយ។

អាសយដ្ឋានរបស់ការិយាល័យចុះបញ្ជី និងទីកន្លែងអាជីវកម្មចម្បង គឺស្ថិតនៅ ផ្ទះលេខ 101A ផ្លូវលេខ 289 សង្កាត់បឹងកក់1 ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ក្រុមហ៊ុនមានបុគ្គលិកចំនួន 170 នាក់ (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021៖ មានចំនួន 126 នាក់)។

## 2. មូលដ្ឋានគណនេយ្យ

### ក. របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ("ស.រ.ទ.ហ.អ.ក សម្រាប់ ស.ត.ម")។

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានអនុម័តឲ្យបោះផ្សាយដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី19 ខែមេសា ឆ្នាំ2023។

ព័ត៌មានលម្អិត ទាក់ទងនឹងគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ 28។

## ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

### កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
### សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

### 2. មូលដ្ឋានគណនេយ្យ (ត)

### ខ. មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយផ្អែកលើមូលដ្ឋានថ្លៃដើមប្រវត្តិសាស្ត្រ។

### 3. រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ

ក្រុមហ៊ុន ធ្វើប្រតិបត្តិការ និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួនជាពីររូបិយប័ណ្ណគឺ ប្រាក់រៀលខ្មែរ និងប្រាក់ដុល្លារអាមេរិក។ អ្នកគ្រប់គ្រង បានកំណត់ថា ប្រាក់ដុល្លារអាមេរិក គឺជារូបិយប័ណ្ណមុខងារ និងជារូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ ព្រោះវាឆ្លុះបញ្ចាំងពីសារធាតុសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន។

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។ តួលេខទាំងអស់ត្រូវបានកាត់ខ្ទង់ចំនួនមួយដុល្លារអាមេរិកដែលជិតបំផុត ឬមួយពាន់រៀល លុះត្រាតែមានការបង្ហាញផ្សេងពីនោះ។

### 4. ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ អ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យ ប៉ាន់ស្មាន និងសន្មតដែលមានផលប៉ះពាល់ដល់ការអនុវត្តនូវគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន និងចំនួននៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលបានរាយការណ៍។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនេះ។

ការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធ ត្រូវបានត្រួតពិនិត្យជាប្រចាំ។ ការកែប្រែលើការប៉ាន់ស្មានគណនេយ្យត្រូវបានទទួលស្គាល់តាមវិធីសាស្ត្រទស្សនវិស័យ។

ព័ត៌មានអំពីភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន ដែលមានហានិភ័យជាសារវន្ត ដែលអាចធ្វើឲ្យមាននិយ័តភាពនៅក្នុងការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ដែលទាក់ទងនឹងឱនភាពនៃតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញដូចខាងក្រោម៖

- កំណត់សម្គាល់ 28ខ(vii) – ការកំណត់ និងការវាស់វែងលើឱនភាពនៃតម្លៃ។

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

## 5. ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិកដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។ ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិក ទៅជាប្រាក់រៀល បានបំពេញតាមលក្ខខណ្ឌតម្រូវនៃការបង្ហាញព័ត៌មានដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ហើយការប្តូររូបិយប័ណ្ណនេះធ្វើឡើងដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ផ្នែកទី30 *ការប្តូររូបិយប័ណ្ណបរទេស*។

ទ្រព្យសកម្ម និងបំណុល ត្រូវបានប្តូររូបិយប័ណ្ណតាមអត្រានាកាលបរិច្ឆេទរាយការណ៍ ហើយដើមទុន និងធាតុផ្សេងៗនៃមូលធន ត្រូវបានប្តូរតាមអត្រាប្រវត្តិសាស្រ្ត។ របាយការណ៍លទ្ធផលលម្អិត និងលំហូរទឹកប្រាក់ត្រូវបានប្តូររូបិយប័ណ្ណទៅជាប្រាក់រៀល ដោយប្រើប្រាស់អត្រាមធ្យមនៅក្នុងការិយបរិច្ឆេទ ដែលអត្រានេះត្រូវបានចាត់ទុកថាមានលក្ខណៈសមស្រប ពីព្រោះអត្រាប្តូររូបិយប័ណ្ណនេះ មិនមានការប្រែប្រួលជាសារវន្តនៅក្នុងការិយបរិច្ឆេទ។ ភាពខុសគ្នាដែលកើតឡើងពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ជា "ទុនបម្រុងពីការប្តូររូបិយប័ណ្ណ" នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ។

ក្រុមហ៊ុនប្រើប្រាស់អត្រាប្តូររូបិយប័ណ្ណដូចខាងក្រោម៖

| | | | អត្រានាកាលបរិច្ឆេទ រាយការណ៍ | អត្រាមធ្យម |
|---|---|---|---|---|
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | 1 ដុល្លារអាមេរិក | = | 4,117 រៀល | 4,087 រៀល |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | 1 ដុល្លារអាមេរិក | = | 4,074 រៀល | 4,068 រៀល |

តួលេខជាប្រាក់រៀលនេះ គឺសម្រាប់ជាការបង្ហាញតែប៉ុណ្ណោះ ហើយមិនត្រូវបានយកមកបកស្រាយថា តួលេខប្រាក់ដុល្លារអាមេរិកនេះត្រូវបានប្តូរទៅជាប្រាក់រៀល ឬគួរត្រូវបានប្តូរជាប្រាក់រៀល ឬនិងត្រូវបានប្តូរជាប្រាក់រៀលនាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ។

## 6. សាច់ប្រាក់ក្នុងដៃ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| សាច់ប្រាក់ក្នុងដៃ | 154,412 | 635,714 | 192,475 | 784,143 |

## 6. សាច់ប្រាក់ក្នុងដៃ (ត)

សម្រាប់គោលបំណងនៃការរៀបចំរបាយការណ៍លំហូរទឹកប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន៖

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| សាច់ប្រាក់ក្នុងដៃ | 154,412 | 635,714 | 192,475 | 784,143 |
| គណនីចរន្តនៅធនាគារជាតិនៃកម្ពុជា (កំណត់សម្គាល់ 8) | 2,382 | 9,807 | 48,744 | 198,583 |
| សមតុល្យនៅធនាគារនានា (កំណត់សម្គាល់ 7) | 741,756 | 3,053,809 | 630,550 | 2,568,861 |
| | 898,550 | 3,699,330 | 871,769 | 3,551,587 |

## 7. សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| គណនីចរន្ត | 256,681 | 1,056,756 | 78,085 | 318,118 |
| គណនីសន្សំ | 485,075 | 1,997,053 | 302,465 | 1,232,243 |
| ប្រាក់បញ្ញើមានកាលកំណត់ដែលមានកាលវសានលើសពី 3ខែ | - | - | 250,000 | 1,018,500 |
| | 741,756 | 3,053,809 | 630,550 | 2,568,861 |

## 7. សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា (ត)

សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា ត្រូវបានវិភាគបន្ថែមទៀតដូចខាងក្រោម៖

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល<br>(កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល<br>(កំណត់សម្គាល់ 5) |
| **ក. តាមកាលវសាន៖** | | | | |
| រយៈពេល 1ខែ | 741,756 | 3,053,809 | 380,550 | 1,550,361 |
| ចន្លោះពី 2 ទៅ 3ខែ | - | - | - | - |
| ចន្លោះពី 4 ទៅ 12ខែ | - | - | 250,000 | 1,018,500 |
| | 741,756 | 3,053,809 | 630,550 | 2,568,861 |

### ខ. តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ)៖

អត្រាការប្រាក់ប្រចាំឆ្នាំដែលអនុវត្តទៅលើសមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា នាចុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 |
|---|---|---|
| គណនីសន្សំ | គ្មាន | គ្មាន |
| ប្រាក់បញ្ញើមានកាលកំណត់ | គ្មាន | 1% |

## 8. សមតុល្យនៅធនាគារជាតិនៃកម្ពុជា

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល<br>(កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល<br>(កំណត់សម្គាល់ 5) |
| គណនីចរន្ត (*) | 2,382 | 9,807 | 48,744 | 198,583 |
| ប្រាក់តម្កល់ធានាលើដើមទុន (**) | 279,650 | 1,151,319 | 279,650 | 1,139,294 |
| | 282,032 | 1,161,126 | 328,394 | 1,337,877 |

## 8. សមតុល្យនៅធនាគារជាតិនៃកម្ពុជា (ត)

(*) នេះតំណាងឲ្យគណនីចរន្តរក្សាទុកនៅធនាគារជាតិនៃកម្ពុជា។ គណនីចរន្ត ពុំមានអត្រាការប្រាក់។

(**) យោងតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ7-01-136 ចុះថ្ងៃទី15 ខែតុលា ឆ្នាំ2001 គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ តម្រូវឲ្យរក្សាទុកប្រាក់តម្កល់ធានាលើដើមទុនស្មើនឹង 5% នៃដើមទុនចុះបញ្ជីជាមួយនឹងធនាគារជាតិនៃកម្ពុជា។ ប្រាក់តម្កល់នេះ គឺមិនអាចយកមកប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុនបានឡើយ ប៉ុន្តែក្រុមហ៊ុនអាចដកមកវិញបាន នៅពេលដែលក្រុមហ៊ុនសម្រេចចិត្តឈប់ធ្វើអាជីវកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រាក់តម្កល់ធានាលើដើមទុន មានអត្រាការប្រាក់ចំនួន 1/2 នៃរយៈពេលប្រាំមួយខែដែលត្រូវបានកំណត់អត្រាការប្រាក់ឡើងវិញដោយធនាគារជាតិនៃកម្ពុជា សម្រាប់ប្រាក់តម្កល់តាមច្បាប់រក្សាទុកជាប្រាក់រៀលខ្មែរ និង 3/8 នៃរយៈពេលប្រាំមួយខែនៃអត្រា SIBOR សម្រាប់ប្រាក់តម្កល់តាមច្បាប់រក្សាទុកជាប្រាក់ដុល្លារអាមេរិក។

## 9. ឥណទានផ្តល់ដល់អតិថិជន

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ឥណទានឯកត្តបុគ្គល | 23,348,175 | 96,124,436 | 15,136,635 | 61,666,651 |
| ឥណទានក្រុម | 128,531 | 529,162 | 18,276 | 74,456 |
| ឥណទានបុគ្គលិក | 205,171 | 844,689 | 347,905 | 1,417,365 |
| **ឥណទានផ្តល់ដល់អតិថិជនដុលសរុប** | 23,681,877 | 97,498,287 | 15,502,816 | 63,158,472 |
| ការប្រាក់បង្គរត្រូវទទួល | 291,713 | 1,200,982 | 201,947 | 822,732 |
| កម្រៃសេវាឥណទានមិនទាន់រំលស់ | (256,248) | (1,054,972) | (136,385) | (555,632) |
| | 23,717,342 | 97,644,297 | 15,568,378 | 63,425,572 |
| ដកៈ សំវិធានធនលើ | | | | |
| ការខាតបង់ឱនភាពនៃតម្លៃ | (390,013) | (1,605,684) | (365,335) | (1,488,375) |
| **ឥណទានផ្តល់ដល់អតិថិជនសរុប-សុទ្ធ** | 23,327,329 | 96,038,613 | 15,203,043 | 61,937,197 |

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

### 9. ឥណទានផ្តល់ដល់អតិថិជន (ត)

បម្រែបម្រួលសំវិធានធនលើការខាតបង់ឱនភាពនៃតម្លៃក្នុងអំឡុងការិយបរិច្ឆេទ មានដូចខាងក្រោម៖

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ថ្ងៃទី1 ខែមករា | 365,335 | 1,488,375 | 284,766 | 1,151,878 |
| ទទួលស្គាល់ក្នុងចំណេញ ឬខាត | 25,304 | 103,417 | 80,580 | 327,799 |
| ការខាតបង់លើរូបិយប័ណ្ណបរទេស | (626) | (2,558) | (11) | (45) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | 16,450 | - | 8,743 |
| ថ្ងៃទី31 ខែធ្នូ | 390,013 | 1,605,684 | 365,335 | 1,488,375 |

ឥណទានផ្តល់ដល់អតិថិជនដុល ត្រូវបានវិភាគដូចខាងក្រោម៖

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **ក. តាមរូបិយប័ណ្ណ៖** | | | | |
| ដុល្លារអាមេរិក | 20,991,597 | 86,422,405 | 13,799,444 | 56,218,935 |
| ប្រាក់រៀលខ្មែរ | 2,690,280 | 11,075,882 | 1,703,372 | 6,939,537 |
| | 23,681,877 | 97,498,287 | 15,502,816 | 63,158,472 |
| **ខ. តាមវិស័យសេដ្ឋកិច្ច៖** | | | | |
| សេវាកម្ម | 7,312,267 | 30,104,603 | 7,352,252 | 29,953,075 |
| អាជីវកម្មគ្រួសារ | 4,995,542 | 20,566,646 | 3,778,306 | 15,392,819 |
| ការជួញដូរ និងពាណិជ្ជកម្ម | 3,052,513 | 12,567,196 | 1,164,393 | 4,743,737 |
| ការសាងសង់ | 2,468,453 | 10,162,621 | 1,366,434 | 5,566,852 |
| កសិកម្ម | 1,656,972 | 6,821,754 | 604,157 | 2,461,336 |
| ការដឹកជញ្ជូន | 429,352 | 1,767,642 | 471,879 | 1,922,435 |
| ផ្សេងៗ | 3,766,778 | 15,507,825 | 765,395 | 3,118,218 |
| | 23,681,877 | 97,498,287 | 15,502,816 | 63,158,472 |
| **គ. តាមនិវាសនដ្ឋាន៖** | | | | |
| និវាសនជន | 23,681,877 | 97,498,287 | 15,502,816 | 63,158,472 |

# ខេមរា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

### 9. ឥណទានផ្តល់ដល់អតិថិជន (ត)

ឥណទានផ្តល់ដល់អតិថិជនដុល ត្រូវបានវិភាគដូចខាងក្រោម៖ (ត)

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **ឃ. តាមទំនាក់ទំនង៖** | | | | |
| សម្ព័ន្ធញាតិ | 30,821 | 126,890 | 76,563 | 311,917 |
| មិនមែនសម្ព័ន្ធញាតិ | 23,651,056 | 97,371,397 | 15,426,253 | 62,846,555 |
| | 23,681,877 | 97,498,287 | 15,502,816 | 63,158,472 |
| **ង. តាមរយៈហានិភ័យ៖** | | | | |
| ហានិភ័យធម្មតា | 23,681,877 | 97,498,287 | 15,502,816 | 63,158,472 |
| **ច. ដោយវត្ថុបញ្ចាំ៖** | | | | |
| ធានា | 23,383,721 | 96,270,779 | 15,458,071 | 62,976,181 |
| គ្មានធានា | 298,156 | 1,227,508 | 44,745 | 182,291 |
| | 23,681,877 | 97,498,287 | 15,502,816 | 63,158,472 |
| **ឆ. ដោយកាលវសាន៖** | | | | |
| កម្ចីមួយឆ្នាំឬតិចជាង | | | | |
| < 15ថ្ងៃ | 78,382 | 322,699 | 304,328 | 1,239,832 |
| 15ថ្ងៃ – 30ថ្ងៃ | 190 | 782 | - | - |
| 31ថ្ងៃ – 60ថ្ងៃ | - | - | 482 | 1,964 |
| 61ថ្ងៃ – 90ថ្ងៃ | 1,158 | 4,767 | 1,373 | 5,594 |
| ≥ 91ថ្ងៃ | 10,523 | 43,323 | 13,861 | 56,470 |
| សរុបរង (ក) | 90,253 | 371,571 | 320,044 | 1,303,860 |
| កម្ចីលើសមួយឆ្នាំ | | | | |
| < 30ថ្ងៃ | 21,470,460 | 88,393,884 | 14,665,484 | 59,747,182 |
| ≥ 30ថ្ងៃ – 89ថ្ងៃ | 1,119,131 | 4,607,462 | 91,758 | 373,822 |
| ≥ 90ថ្ងៃ – 179ថ្ងៃ | 240,348 | 989,513 | 70,479 | 287,131 |
| ≥ 180ថ្ងៃ – 359ថ្ងៃ | 208,168 | 857,028 | 53,548 | 218,155 |
| លើស 359ថ្ងៃ | 553,517 | 2,278,829 | 301,503 | 1,228,322 |
| សរុបរង (ខ) | 23,591,624 | 97,126,716 | 15,182,772 | 61,854,612 |
| សរុប (ក+ខ) | 23,681,877 | 97,498,287 | 15,502,816 | 63,158,472 |

### 9. ឥណទានផ្តល់ដល់អតិថិជន (ត)

ឥណទានផ្តល់ដល់អតិថិជនដុល ត្រូវបានវិភាគដូចខាងក្រោម៖ (ត)

#### ជ. តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ)៖

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 |
|---|---|---|
| ឥណទានឯកត្តបុគ្គល | 6.50% - 18.00% | 6.50% - 18.00% |
| ឥណទានក្រុម | 18.00% | 18.00% |
| ឥណទានបុគ្គលិក | 13.20% - 15.60% | 13.20% - 15.60% |

### 10. ទ្រព្យសកម្មផ្សេងៗ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| *រយៈពេលខ្លី៖* | | | | |
| ប្រាក់បង់មុន | 81,188 | 334,251 | 32,812 | 133,676 |
| ផ្សេងៗ | 40,910 | 168,427 | 25,806 | 105,134 |
| *រយៈពេលវែង៖* | | | | |
| ប្រាក់កក់ | 35,134 | 144,647 | 37,400 | 152,368 |
| | 157,232 | 647,325 | 96,018 | 391,178 |

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

## 11. ទ្រព្យ និងបរិក្ខារ

| 2022 | ការកែលម្អទ្រព្យជួល<br>ដុល្លារអាមេរិក | បរិក្ខារការិយាល័យ<br>ដុល្លារអាមេរិក | បរិក្ខារកុំព្យូទ័រ និងព័ត៌មានវិទ្យា<br>ដុល្លារអាមេរិក | យានយន្ត<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក | សរុប<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) |
|---|---|---|---|---|---|---|
| **ថ្លៃដើម** | | | | | | |
| ថ្ងៃទី1 ខែមករា ឆ្នាំ2022 | 94,470 | 102,030 | 128,941 | 19,800 | 345,241 | 1,406,512 |
| ការទិញបន្ថែម | 31,009 | 37,405 | 38,183 | 7,348 | 113,945 | 465,693 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | 18,264 |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | 125,479 | 139,435 | 167,124 | 27,148 | 459,186 | 1,890,469 |
| ដកៈ **រំលស់បង្គរ** | | | | | | |
| ថ្ងៃទី1 ខែមករា ឆ្នាំ2022 | 83,786 | 69,891 | 95,919 | 19,800 | 269,396 | 1,097,519 |
| រំលស់ក្នុងការិយបរិច្ឆេទ | 6,974 | 16,486 | 16,096 | 941 | 40,497 | 165,511 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | 12,799 |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | 90,760 | 86,377 | 112,015 | 20,741 | 309,893 | 1,275,829 |
| **តម្លៃយោង** | | | | | | |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | 34,719 | 53,058 | 55,109 | 6,407 | 149,293 | 614,640 |

រួមបញ្ចូលក្នុងថ្លៃដើមនៃទ្រព្យ និងបរិក្ខារមានថ្លៃដើមចំនួន 264,969 ដុល្លារអាមេរិក ត្រូវបានរំលស់ទាំងស្រុងនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 (នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2021៖ 259,411 ដុល្លារអាមេរិក) ប៉ុន្តែនៅអាចបន្តប្រើប្រាស់បាននៅឡើយ។

### 11. ទ្រព្យ និងបរិក្ខារ (ត)

| 2021 | ការកែលម្អទ្រព្យជួល<br>ដុល្លារអាមេរិក | បរិក្ខារការិយាល័យ<br>ដុល្លារអាមេរិក | បរិក្ខារកុំព្យូទ័រ និងព័ត៌មានវិទ្យា<br>ដុល្លារអាមេរិក | យានយន្ត<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក | សរុប<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) |
|---|---|---|---|---|---|---|
| **ថ្លៃដើម** | | | | | | |
| ថ្ងៃទី1 ខែមករា ឆ្នាំ2021 | 94,276 | 87,423 | 97,940 | 19,800 | 299,439 | 1,211,231 |
| ការទិញបន្ថែម | 655 | 15,450 | 31,391 | - | 47,496 | 193,499 |
| ការលុបចោល | - | - | (600) | - | (600) | (2,444) |
| និយ័តភាព | (461) | (843) | 210 | - | (1,094) | (4,457) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | 8,683 |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | 94,470 | 102,030 | 128,941 | 19,800 | 345,241 | 1,406,512 |
| ដក៖ **រំលស់បង្គរ** | | | | | | |
| ថ្ងៃទី1 ខែមករា ឆ្នាំ2021 | 79,420 | 54,104 | 81,889 | 19,800 | 235,213 | 951,437 |
| រំលស់ក្នុងការិយបរិច្ឆេទ | 4,827 | 16,630 | 14,420 | - | 35,877 | 145,948 |
| ការលុបចោល | - | - | (600) | - | (600) | (2,444) |
| និយ័តភាព | (461) | (843) | 210 | - | (1,094) | (4,457) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | 7,035 |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | 83,786 | 69,891 | 95,919 | 19,800 | 269,396 | 1,097,519 |
| **តម្លៃយោង** | | | | | | |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | 10,684 | 32,139 | 33,022 | - | 75,845 | 308,993 |

# ខេមរា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

### 12. ទ្រព្យសកម្មអរូបី

| | កុំព្យូទ័រសូហ្វវែរ | | | |
|---|---|---|---|---|
| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **ថ្លៃដើម** | | | | |
| ថ្ងៃទី1 ខែមករា | 52,680 | 214,618 | 52,788 | 213,527 |
| ការទិញបន្ថែម | 39,484 | 161,371 | - | - |
| និយ័តភាព | - | - | (108) | (440) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | 3,450 | - | 1,531 |
| ថ្ងៃទី31 ខែធ្នូ | 92,164 | 379,439 | 52,680 | 214,618 |
| ដកៈ **រំលស់បង្គរ** | | | | |
| ថ្ងៃទី1 ខែមករា | 52,680 | 214,618 | 46,004 | 186,086 |
| រំលស់ក្នុងការិយបរិច្ឆេទ | 3,205 | 13,099 | 6,784 | 27,597 |
| និយ័តភាព | - | - | (108) | (440) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | 2,362 | - | 1,375 |
| ថ្ងៃទី31 ខែធ្នូ | 55,885 | 230,079 | 52,680 | 214,618 |
| **តម្លៃយោង** | | | | |
| ថ្ងៃទី31 ខែធ្នូ | 36,279 | 149,361 | - | - |

រួមបញ្ចូលក្នុងថ្លៃដើមនៃទ្រព្យសកម្មអរូបីមានថ្លៃដើមចំនួន 52,680 ដុល្លារអាមេរិក ត្រូវបានរំលស់ទាំងស្រុងនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 និង ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 ប៉ុន្តែនៅអាចបន្តប្រើប្រាស់បាននៅឡើយ។

### 13. ប្រាក់កម្ចី

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| *រយៈពេលខ្លីៈ* | | | | |
| សាជីវកម្ម | 3,331,182 | 13,714,476 | - | - |
| ឯកត្តជន | 5,494,000 | 22,618,798 | 3,323,873 | 13,541,459 |
| | 8,825,182 | 36,333,274 | 3,323,873 | 13,541,459 |

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

## 13. ប្រាក់កម្ចី (ត)

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| *រយៈពេលវែង៖* | | | | |
| សាជីវកម្ម | 5,851,586 | 24,090,980 | 1,839,232 | 7,493,031 |
| ឯកត្តជន | 534,724 | 2,201,459 | 4,191,667 | 17,076,851 |
| | 6,386,310 | 26,292,439 | 6,030,899 | 24,569,882 |
| ប្រាក់កម្ចីសរុបដុល | 15,211,492 | 62,625,713 | 9,354,772 | 38,111,341 |
| បូក៖ ការប្រាក់បង្គរត្រូវទូទាត់ | 129,585 | 533,501 | 122,432 | 498,788 |
| | 15,341,077 | 63,159,214 | 9,477,204 | 38,610,129 |

ការផ្ទៀងផ្ទាត់នៃបម្រែបម្រួលនៃបំណុលធៀបនឹងលំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន និងលំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ៖

| | 2022 | | 2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **ប្រាក់កម្ចីដុល** | | | | |
| ថ្ងៃទី1 ខែមករា | 9,354,772 | 38,111,341 | 8,893,158 | 35,972,824 |
| **បម្រែបម្រួលពីលំហូរទឹកប្រាក់ហិរញ្ញប្បទាន** | | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | 16,477,548 | 67,343,739 | 8,807,064 | 35,827,136 |
| ការទូទាត់សងប្រាក់កម្ចី | (10,594,547) | (43,299,914) | (8,345,450) | (33,949,291) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | 578,745 | - | 260,672 |
| | 15,237,773 | 62,733,911 | 9,354,772 | 38,111,341 |
| រំលស់កម្រៃសេវាប្រាក់កម្ចី | (26,281) | (107,410) | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (788) | - | - |
| | 15,211,492 | 62,625,713 | 9,354,772 | 38,111,341 |

## 13. ប្រាក់កម្ចី (ត)

ការផ្ទៀងផ្ទាត់នៃបម្រែបម្រួលនៃបំណុលធៀបនឹងលំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន និងលំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការៈ (ត)

| | 2022 | | 2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **ការប្រាក់បង្គរត្រូវបង់** | | | | |
| ថ្ងៃទី1 ខែមករា | 122,432 | 498,788 | 143,073 | 578,730 |
| **បម្រែបម្រួលពីលំហូរទឹកប្រាក់ប្រតិបត្តិការ** | | | | |
| ចំណាយលើការប្រាក់ | 621,726 | 2,540,994 | 535,366 | 2,177,869 |
| ការប្រាក់បានបង់ | (614,573) | (2,511,760) | (556,007) | (2,261,836) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | 5,479 | - | 4,025 |
| | 129,585 | 533,501 | 122,432 | 498,788 |
| ថ្ងៃទី31 ខែធ្នូ | 15,341,077 | 63,159,214 | 9,477,204 | 38,610,129 |

សមតុល្យប្រាក់កម្ចី ត្រូវបានវិភាគដូចខាងក្រោមៈ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **ក. តាមកាលវសានៈ** | | | | |
| រយៈពេល 1ខែ | 700,000 | 2,881,900 | 751,403 | 3,061,216 |
| ចន្លោះពី 2 ទៅ 3ខែ | 1,200,000 | 4,940,400 | 700,000 | 2,851,800 |
| ចន្លោះពី 4 ទៅ 12ខែ | 6,925,180 | 28,510,966 | 1,884,235 | 7,676,373 |
| ចន្លោះពី 1 ទៅ 5ឆ្នាំ | 5,258,655 | 21,649,883 | 4,771,482 | 19,439,018 |
| លើសពី 5ឆ្នាំ | 1,127,657 | 4,642,564 | 1,247,652 | 5,082,934 |
| | 15,211,492 | 62,625,713 | 9,354,772 | 38,111,341 |

## 13. ប្រាក់កម្ចី (ត)

សមតុល្យប្រាក់កម្ចី ត្រូវបានវិភាគដូចខាងក្រោម៖ (ត)

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **ខ. តាមរូបិយប័ណ្ណ៖** | | | | |
| ប្រាក់រៀលខ្មែរ | 1,480,677 | 6,095,947 | 153,661 | 626,016 |
| ប្រាក់ដុល្លារអាមេរិក | 13,730,815 | 56,529,766 | 9,201,111 | 37,485,325 |
| | 15,211,492 | 62,625,713 | 9,354,772 | 38,111,341 |
| **គ. តាមរយៈទំនាក់ទំនង៖** | | | | |
| សម្ព័ន្ធញាតិ | 3,234,724 | 13,317,359 | 4,093,069 | 16,675,163 |
| មិនមែនសម្ព័ន្ធញាតិ | 11,976,768 | 49,308,354 | 5,261,703 | 21,436,178 |
| | 15,211,492 | 62,625,713 | 9,354,772 | 38,111,341 |

**ឃ. តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ)៖**

អត្រាការប្រាក់ប្រចាំឆ្នាំលើប្រាក់កម្ចីនាចុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 |
|---|---|---|
| ប្រាក់រៀលខ្មែរ | 2.00% - 8.00% | 2.00% - 6.00% |
| ប្រាក់ដុល្លារអាមេរិក | 2.00% - 7.00% | 2.00% - 7.50% |

## 14. អនុបំណុល

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| អនុបំណុល (*) | 2,202,043 | 9,065,811 | - | - |

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

### 14. អនុបំណុល (ត)

(*) អនុបំណុលដែលមានចំនួនសរុប 2,750,000 ដុល្លារអាមេរិកទទួលបានពីលោកស្រី ឌិត នីតា ដែលជាភាគទុនិក ដោយមានការអនុម័តពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី9 ខែមីនា ឆ្នាំ2022។ ក្នុងអំឡុងការិយបរិច្ឆេទ អនុបំណុលដែលមានចំនួន 550,000 ដុល្លារអាមេរិក ត្រូវបានទូទាត់ទៅកាន់ម្ចាស់បំណុល ដោយមានការអនុម័តពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី23 ខែធ្នូ ឆ្នាំ2022។

ការផ្ទៀងផ្ទាត់នៃបម្រែបម្រួលនៃអនុបំណុលធៀបនឹងលំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន និងលំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ៖

| | 2022 | | 2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **អនុបំណុលដុល** | | | | |
| ថ្ងៃទី1 ខែមករា | - | - | - | - |
| **បម្រែបម្រួលពីលំហូរទឹកប្រាក់ហិរញ្ញប្បទាន** | | | | |
| សាច់ប្រាក់ទទួលបានពីអនុបំណុល | 2,750,000 | 11,239,250 | - | - |
| ការទូទាត់សងអនុបំណុល | (550,000) | (2,247,850) | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | 66,000 | - | - |
| | 2,200,000 | 9,057,400 | - | - |
| រំលស់កម្រៃសេវាប្រាក់កម្ចី | 23 | 94 | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | 1 | - | - |
| | 2,200,023 | 9,057,495 | - | - |
| **ការប្រាក់បង្គរត្រូវបង់** | | | | |
| ថ្ងៃទី1 ខែមករា | - | - | - | - |
| **បម្រែបម្រួលពីលំហូរទឹកប្រាក់ប្រតិបត្តិការ** | | | | |
| ចំណាយលើការប្រាក់ | 178,900 | 731,164 | - | - |
| ការប្រាក់បានបង់ | (176,880) | (722,909) | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | 61 | - | - |
| | 2,020 | 8,316 | - | - |
| ថ្ងៃទី31 ខែធ្នូ | 2,202,043 | 9,065,811 | - | - |

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

## 15. បំណុលផ្សេងៗ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| សំវិធានធនលើកំណត់ពន្ធឡើងវិញ (កំណត់សម្គាល់ 27ខ) | 38,490 | 158,463 | - | - |
| ប្រាក់បង់មុនបានពីអតិថិជន | 29,161 | 120,056 | 27,841 | 113,424 |
| កម្រៃវិជ្ជាជីវៈ | 27,775 | 114,350 | 16,548 | 67,417 |
| ប្រាក់បង្គរ និងប្រាក់ត្រូវបង់ផ្សេងៗ | 21,170 | 87,157 | 2,811 | 11,452 |
| ប្រាក់រំលឹកអតីតភាពការងារ | 10,463 | 43,076 | 12,868 | 52,424 |
| ប្រាក់រង្វាន់បង្គរ | 13,248 | 54,542 | 2,500 | 10,185 |
| ពន្ធកាត់ទុកត្រូវទូទាត់ | 11,386 | 46,876 | 6,702 | 27,304 |
| បំណុលផ្សេងៗ | 3,373 | 13,887 | 1,362 | 5,549 |
| | 155,066 | 638,407 | 70,632 | 287,755 |

## 16. ពន្ធលើប្រាក់ចំណេញ

### ក. អត្រាពន្ធផ្លូវការ

អនុលោមតាមច្បាប់ស្តីពីសារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញសាជីវកម្ម ដោយគណនាតាមអត្រា 20% នៃប្រាក់ចំណេញជាប់ពន្ធ ឬក៏បង់ពន្ធអប្បបរមា ដោយគណនាតាមអត្រា 1% នៃប្រាក់ចំណូលសរុប ទៅតាមចំនួនមួយណាដែលធំជាង។

យោងតាមប្រកាសលេខ 638 ចុះថ្ងៃទី4 ខែកក្កដា ឆ្នាំ2017 អង្គភាពត្រូវបានលើកលែងពីការបង់ពន្ធអប្បបរមា ប្រសិនបើខ្លួនរក្សាកំណត់ត្រាបញ្ជីគណនេយ្យបានត្រឹមត្រូវ និងទទួលបានការអនុម័តពីអគ្គនាយកដ្ឋានពន្ធដារ។

ក្រុមហ៊ុនបានទទួលវិញ្ញាបនបត្រកត់ត្រាបញ្ជីគណនេយ្យបានត្រឹមត្រូវ និងវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទមាស ពីអគ្គនាយកដ្ឋានពន្ធដារនៅថ្ងៃទី13 ខែសីហា ឆ្នាំ2021 និង នៅថ្ងៃទី16 ខែសីហា ឆ្នាំ2021 រៀងគ្នា។ ក្រុមហ៊ុន ត្រូវបានលើកលែងនូវការបង់ពន្ធអប្បបរមា សម្រាប់ឆ្នាំ2021 និងឆ្នាំ2022។

ក្នុងអំឡុងការិយបរិច្ឆេទ ក្រុមហ៊ុនបានទទួលវិញ្ញាបនបត្រកត់ត្រាបញ្ជីគណនេយ្យបានត្រឹមត្រូវ និងវិញ្ញាបនបត្រអនុលោមភាព សារពើពន្ធប្រភេទមាស ពីអគ្គនាយកដ្ឋានពន្ធដារនៅថ្ងៃទី5 ខែកញ្ញា ឆ្នាំ2022 និង នៅថ្ងៃទី8 ខែកញ្ញា ឆ្នាំ2022 រៀងគ្នា។ ក្រុមហ៊ុន ត្រូវបានលើកលែងនូវការបង់ពន្ធអប្បបរមា សម្រាប់ឆ្នាំ2023 និងឆ្នាំ2024។

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

## 16. ពន្ធលើប្រាក់ចំណេញ (ត)

### ខ. ចំណាយពន្ធលើប្រាក់ចំណេញ

| | 2022 | | 2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ចំណាយពន្ធប្រចាំឆ្នាំ | 99,950 | 408,496 | 30,912 | 125,750 |
| ចំណាយពន្ធពន្យារ | (38,397) | (156,929) | 45,274 | 184,175 |
| | 61,553 | 251,567 | 76,186 | 309,925 |

## 16. ពន្ធលើប្រាក់ចំណេញ (ត)

### ខ. ចំណាយពន្ធលើប្រាក់ចំណេញ (ត)

ការផ្ទៀងផ្ទាត់ចំណាយពន្ធលើប្រាក់ចំណេញដែលត្រូវបានគណនាតាមអត្រាពន្ធផ្លូវការ 20% ធៀបទៅនឹងចំណាយពន្ធលើប្រាក់ចំណេញ ដែលបានបង្ហាញនៅក្នុងចំណេញ ឬខាត មានដូចខាងក្រោមៈ

| | 2022 | | | 2021 | | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | % | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | % |
| ប្រាក់ចំណេញមុនដកពន្ធ | 205,943 | 841,689 | | 341,252 | 1,388,213 | |
| ពន្ធលើប្រាក់ចំណេញតាមអត្រាពន្ធផ្លូវការ 20% | 41,189 | 168,339 | 20% | 68,250 | 277,641 | 20% |
| ចំណាយមិនអាចកាត់កងបាន | 11,754 | 48,039 | 6% | 7,936 | 32,284 | 2% |
| ពន្ធពន្យារដែលមិនបានទទួលស្គាល់ពីការិយបរិច្ឆេទមុន | 8,610 | 35,189 | 4% | - | - | - |
| ចំណាយពន្ធលើប្រាក់ចំណេញ | 61,553 | 251,567 | 30% | 76,186 | 309,925 | 22% |

ការគណនាប្រាក់ចំណេញជាប់ពន្ធ គឺស្ថិតក្រោមការត្រួតពិនិត្យ និងវាយតម្លៃចុងក្រោយពីអាជ្ញាធរពន្ធដារ។

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

## 16. ពន្ធលើប្រាក់ចំណេញ (ត)

### គ. បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ

| | 2022 | | 2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ថ្ងៃទី1 ខែមករា | 10,108 | 41,180 | 28,765 | 116,354 |
| ទទួលស្គាល់ក្នុងចំណេញ ឬខាត | 99,950 | 408,496 | 30,912 | 125,750 |
| ពន្ធលើប្រាក់ចំណេញបានបង់ | (34,285) | (140,123) | (49,569) | (201,647) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | 2,404 | - | 723 |
| ថ្ងៃទី31 ខែធ្នូ | 75,773 | 311,957 | 10,108 | 41,180 |

### ឃ. ពន្ធពន្យារសុទ្ធជាបំណុល

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ពន្ធពន្យារជាទ្រព្យសកម្ម | 56,127 | 231,075 | 40,254 | 163,994 |
| ពន្ធពន្យារជាបំណុល | (57,320) | (235,987) | (79,844) | (325,284) |
| ពន្ធពន្យារសុទ្ធជាបំណុល | (1,193) | (4,912) | (39,590) | (161,290) |

## 16. ពន្ធលើប្រាក់ចំណេញ (ត)

### ឃ. ពន្ធពន្យារសុទ្ធជាបំណុល (ត)

ពន្ធពន្យារជាទ្រព្យសកម្ម/(បំណុល) រួមមានដូចខាងក្រោម៖

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| សំវិធានធនលើការខាតបង់ ឱនភាពនៃតម្លៃ | (52,390) | (215,690) | (79,844) | (325,284) |
| កម្រៃសេវាប្រាក់កម្ចីដែល មិនទាន់ទទួលស្គាល់ | (4,930) | (20,297) | - | - |
| កម្រៃសេវាឥណទានដែល មិនទាន់ទទួលស្គាល់ | 51,249 | 210,992 | 27,277 | 111,126 |
| ប្រាក់ខាតពីការប្តូររូបិយប័ណ្ណបរទេស ដែលមិនបានទទួលស្គាល់ | 2,785 | 11,466 | 8,602 | 35,045 |
| ទ្រព្យ និងបរិក្ខារ | - | - | 1,801 | 7,337 |
| សំវិធានធនផ្សេងៗ | 2,093 | 8,617 | 2,574 | 10,486 |
| | (1,193) | (4,912) | (39,590) | (161,290) |

បម្រែបម្រួលពន្ធពន្យារសុទ្ធជាទ្រព្យសកម្ម/(បំណុល) រួមមានដូចខាងក្រោម៖

| | 2022 | | 2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ថ្ងៃទី1 ខែមករា | (39,590) | (161,290) | 5,684 | 22,992 |
| ទទួលស្គាល់ក្នុងចំណេញ ឬខាត | 38,397 | 156,929 | (45,274) | (184,175) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (551) | - | (107) |
| ថ្ងៃទី31 ខែធ្នូ | (1,193) | (4,912) | (39,590) | (161,290) |

## 17. ដើមទុន

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| បានចុះបញ្ជី បោះផ្សាយ និងបង់គ្រប់ចំនួន 5,593,000 ភាគហ៊ុនធម្មតាដែលមានតម្លៃចារិក 1 ដុល្លារអាមេរិកក្នុងមួយហ៊ុន | 5,593,000 | 22,372,000 | 5,593,000 | 22,372,000 |

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ភាគទុនិករបស់ក្រុមហ៊ុន និងភាគកម្មមានដូចខាងក្រោម៖

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022/2021 | | |
|---|---|---|---|
| | % នៃកម្មសិទ្ធិ | ចំនួនភាគហ៊ុន | ទឹកប្រាក់ ដុល្លារអាមេរិក |
| លោកជំទាវ អ៊ូ សាន | 59.69% | 3,338,554 | 3,338,554 |
| លោកស្រី ឌិត នីតា | 40.31% | 2,254,446 | 2,254,446 |
| | 100.00% | 5,593,000 | 5,593,000 |
| សមមូលពាន់រៀល (កំណត់សម្គាល់ 5) | | | 22,372,000 |

ពុំមានការប្រែប្រួលភាគទុនិក និងរចនាសម្ព័ន្ធភាគហ៊ុនរបស់ក្រុមហ៊ុន ក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ។

នៅថ្ងៃទី12 ខែមេសា ឆ្នាំ2021 ក្រុមហ៊ុនបានស្នើសុំទៅធនាគារជាតិនៃកម្ពុជា ដើម្បីបង្កើនដើមទុនពី 3,593,000 ដុល្លារអាមេរិក ទៅ 5,593,000 ដុល្លារអាមេរិក។ នៅថ្ងៃទី12 ខែមករា ឆ្នាំ2022 ក្រុមហ៊ុនបានទទួលការអនុម័តពីធនាគារជាតិនៃកម្ពុជា លើការបង្កើនដើមទុននេះ។ វិសោធនកម្មលើអនុស្សរណៈ និងលក្ខន្តិកៈក្រុមហ៊ុនត្រូវបានអនុម័តដោយក្រសួងពាណិជ្ជកម្មនាថ្ងៃទី9 ខែកុម្ភៈ ឆ្នាំ2022។

## 18. ទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងតាមបទប្បញ្ញត្តិ សំដៅទៅលើភាពខុសគ្នានៃសំវិធានធនរវាងឱនភាពនៃតម្លៃលើឥណទាន ផ្តល់ដល់អតិថិជន ស្របតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម និងការធ្វើសំវិធានធនតាមបទប្បញ្ញត្តិ ដោយអនុលោមតាមធនាគារជាតិនៃកម្ពុជា។

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ក្រុមហ៊ុនបានផ្ទេរពីគណនីទុនបម្រុងតាមបទប្បញ្ញត្តិទៅប្រាក់ចំណេញរក្សាទុក ចំនួន 41,294 ដុល្លារអាមេរិក ដែលមកពីភាពខុសគ្នារវាងឱនភាពលើតម្លៃឥណទានផ្តល់ដល់អតិថិជន ស្របតាមសំវិធានធនតាមបទប្បញ្ញត្តិ ដោយអនុលោមតាមធនាគារជាតិនៃកម្ពុជា និង ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (2021៖ បានផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅគណនីទុនបម្រុងតាមបទប្បញ្ញត្តិ ចំនួន 223,449 ដុល្លារអាមេរិក)។

| | សរុប<br>ដុល្លារអាមេរិក |
|---|---|
| **ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022** | |
| សំវិធានធនតាមធនាគារជាតិនៃកម្ពុជា | 929,762 |
| សំវិធានធនលើឥណទានផ្តល់ដល់អតិថិជនតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម | (390,013) |
| ទុនបម្រុងតាមបទប្បញ្ញត្តិ (ក) | 539,749 |
| **ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021** | |
| សំវិធានធនតាមធនាគារជាតិនៃកម្ពុជា | 946,378 |
| សំវិធានធនលើឥណទានផ្តល់ដល់អតិថិជនតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម | (365,335) |
| ទុនបម្រុងតាមបទប្បញ្ញត្តិ (ខ) | 581,043 |
| ការផ្ទេរពីទុនបម្រុងតាមបទប្បញ្ញត្តិទៅប្រាក់ចំណេញរក្សាទុក (ក) – (ខ) | (41,294) |
| ពាន់រៀល (កំណត់សម្គាល់ 5) | (170,007) |

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

## 19. ចំណូលពីការប្រាក់

| | 2022 | | 2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ឥណទានផ្តល់ដល់អតិថិជន | 2,789,298 | 11,399,861 | 2,142,553 | 8,715,906 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | 1,027 | 4,197 | 132 | 537 |
| សមតុល្យនៅធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុនានា | 166 | 679 | 3,758 | 15,287 |
| | 2,790,491 | 11,404,737 | 2,146,443 | 8,731,730 |

## 20. ចំណាយលើការប្រាក់

| | 2022 | | 2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| *រយៈពេលខ្លី៖* | | | | |
| ប្រាក់កម្ចី | 372,251 | 1,521,390 | 300,566 | 1,222,702 |
| *រយៈពេលវែង៖* | | | | |
| ប្រាក់កម្ចី | 249,475 | 1,019,605 | 234,800 | 955,167 |
| អនុបំណុល | 178,900 | 731,163 | - | - |
| | 800,626 | 3,272,158 | 535,366 | 2,177,869 |

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

## 21. ចំណូលពីប្រតិបត្តិការផ្សេងៗ

| | 2022 | | 2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| កម្រៃជាកពិន័យ | 113,546 | 464,062 | 152,822 | 621,680 |
| ចំណូលពីការជួល | 5,013 | 20,488 | 5,715 | 23,249 |
| ខាតពីការប្តូររូបិយប័ណ្ណបរទេស ដែលបានទទួលស្គាល់ – សុទ្ធ | (718) | (2,935) | (433) | (1,762) |
| ខាតពីការប្តូររូបិយប័ណ្ណបរទេស ដែលមិនបានទទួលស្គាល់ – សុទ្ធ | (15,809) | (64,611) | (8,999) | (36,608) |
| | 102,032 | 417,004 | 149,105 | 606,559 |

## 22. ចំណាយលើបុគ្គលិក

| | 2022 | | 2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ប្រាក់បៀវត្សរ៍ | 1,015,578 | 4,150,667 | 790,418 | 3,215,420 |
| ប្រាក់រង្វាន់ | 95,637 | 390,868 | 64,103 | 260,771 |
| ការរួមចំណែកមូលនិធិសន្តិសុខជាតិ | 22,733 | 92,910 | 16,064 | 65,348 |
| វគ្គបណ្តុះបណ្តាល | 13,982 | 57,145 | 3,062 | 12,456 |
| ផ្សេងៗ | 81,367 | 332,547 | 76,929 | 312,948 |
| | 1,229,297 | 5,024,137 | 950,576 | 3,866,943 |

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

## 23. រំលស់លើទ្រព្យរូបី និងទ្រព្យអរូបី

| | 2022 | | 2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| រំលស់លើទ្រព្យរូបី (កំណត់សម្គាល់ 11) | 40,497 | 165,511 | 35,877 | 145,948 |
| រំលស់លើទ្រព្យអរូបី (កំណត់សម្គាល់ 12) | 3,205 | 13,099 | 6,784 | 27,597 |
| | 43,702 | 178,610 | 42,661 | 173,545 |

## 24. ចំណាយលើប្រតិបត្តិការផ្សេងៗ

| | 2022 | | 2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| ចំណាយលើការជួល | 144,498 | 590,563 | 116,888 | 475,500 |
| កម្រៃវិជ្ជាជីវៈ | 92,564 | 378,309 | 36,794 | 149,678 |
| កម្រៃ និងពន្ធ | 89,731 | 366,731 | 37,986 | 154,527 |
| ចំណាយលើការធ្វើដំណើរ និងយានយន្ត | 63,981 | 261,490 | 34,950 | 142,177 |
| ចំណាយលើសម្ភារៈ និងបរិក្ខារការិយាល័យ | 44,658 | 182,517 | 18,335 | 74,587 |
| ថ្លៃសេវាសន្តិសុខ | 29,689 | 121,339 | 25,316 | 102,985 |
| ចំណាយទឹកភ្លើង | 28,509 | 116,516 | 21,971 | 89,378 |
| ការជួសជុល និងថែទាំ | 27,317 | 111,645 | 22,128 | 90,017 |
| ចំណាយលើការផ្សព្វផ្សាយ | 28,225 | 115,356 | 9,882 | 40,200 |
| ចំណាយលើទំនាក់ទំនង | 15,232 | 62,253 | 14,120 | 57,440 |
| ចំណាយលើការកម្សាន្ត | 10,345 | 42,280 | - | - |
| ចំណាយលើការបោះពុម្ព និងថតចម្លង | 1,245 | 5,088 | 722 | 2,937 |
| ចំណាយផ្សេងៗ | 11,657 | 47,643 | 6,021 | 24,494 |
| | 587,651 | 2,401,730 | 345,113 | 1,403,920 |

## 25. សម្ព័ន្ធញាតិ

### ក. អត្តសញ្ញាណរបស់សម្ព័ន្ធញាតិ

សម្ព័ន្ធញាតិ និងទំនាក់ទំនងរបស់ពួកគេជាមួយក្រុមហ៊ុនមានដូចខាងក្រោម៖

| **ទំនាក់ទំនង** | **សម្ព័ន្ធញាតិ** |
|---|---|
| ភាគទុនិក៖ | យោងតាមកំណត់សម្គាល់ 17 |
| លោកជំទាវ អ៊ូ សាន | |
| លោកស្រី ឌិត នីតា | |
| អ្នកគ្រប់គ្រងសំខាន់ៗ | អភិបាលរបស់ក្រុមហ៊ុនទាំងអស់ ដែលធ្វើការសម្រេចចិត្តសំខាន់ៗទាក់ទងនឹងទិសដៅយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន និងបុគ្គលិកគ្រប់គ្រងជាន់ខ្ពស់ (រួមទាំងសមាជិកគ្រួសារជិតស្និទ្ធរបស់ពួកគេ)។ |

### ខ. ប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ

| | 2022 | | 2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **សមាជិកគ្រួសារជិតស្និតរបស់ភាគទុនិក** | | | | |
| ចំណាយលើការប្រាក់ | 333,653 | 1,363,640 | 235,720 | 958,909 |
| **អ្នកគ្រប់គ្រងសំខាន់ៗ** | | | | |
| **(ចាប់ពីអ្នកគ្រប់គ្រងក្រុមហ៊ុនឡើង)** | | | | |
| ចំណូលពីការប្រាក់ | 7,885 | 32,226 | 10,064 | 40,940 |
| លាភការអ្នកគ្រប់គ្រងសំខាន់ៗ | 317,161 | 1,296,237 | 271,603 | 1,104,881 |

## 25. សម្ព័ន្ធញាតិ (ត)

### គ. សមតុល្យជាមួយសម្ព័ន្ធញាតិ

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **សមាជិកគ្រួសារជិតស្និតរបស់ភាគទុនិក** | | | | |
| ប្រាក់កម្ចី | 3,234,724 | 13,317,359 | 4,093,069 | 16,675,163 |
| អនុបំណុល | 2,200,023 | 9,057,495 | - | - |
| ការប្រាក់បង្គរត្រូវទូទាត់ | 65,310 | 268,881 | 47,245 | 192,476 |
| **អ្នកគ្រប់គ្រងសំខាន់ៗ (ចាប់ពីអ្នកគ្រប់គ្រងក្រុមហ៊ុនឡើង)** | | | | |
| ឥណទានផ្តល់ដល់បុគ្គលិក | 30,821 | 126,890 | 76,563 | 311,918 |
| ការប្រាក់បង្គរត្រូវទទួល | 222 | 914 | 583 | 2,375 |

## 26. ចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

តារាងខាងក្រោម បង្ហាញការផ្ទៀងផ្ទាត់រវាងធាតុនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងចំណាត់ថ្នាក់នៃឧបករណ៍ហិរញ្ញវត្ថុ។

| | តម្លៃសមស្របតាម ចំណេញ ឬខាត | តម្លៃសមស្របតាម លទ្ធផលលម្អិតផ្សេងៗ | តាម រំលស់ថ្លៃដើម | ដក ឱនភាពនៃតម្លៃ | តម្លៃយោងសរុប | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022** | | | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | |
| សាច់ប្រាក់ក្នុងដៃ | - | - | 154,412 | - | 154,412 | 635,714 |
| សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា | - | - | 741,756 | - | 741,756 | 3,053,809 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | - | - | 282,032 | - | 282,032 | 1,161,126 |
| ឥណទានផ្តល់ដល់អតិថិជន | - | - | 23,717,342 | (390,013) | 23,327,329 | 96,038,613 |
| ទ្រព្យសកម្មផ្សេងៗ | - | - | 157,232 | - | 157,232 | 647,325 |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | - | - | 25,052,774 | (390,013) | 24,662,761 | 101,536,587 |

## 26. ចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

តារាងខាងក្រោម បង្ហាញការផ្ទៀងផ្ទាត់រវាងធាតុនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងចំណាត់ថ្នាក់នៃឧបករណ៍ហិរញ្ញវត្ថុ។ (ត)

| | តម្លៃសមស្របតាម ចំណេញ ឬខាត ដុល្លារអាមេរិក | តម្លៃសមស្របតាម លទ្ធផលលម្អិតផ្សេងៗ ដុល្លារអាមេរិក | តាម រំលស់ថ្លៃដើម ដុល្លារអាមេរិក | ដក ឱនភាពនៃតម្លៃ ដុល្លារអាមេរិក | តម្លៃយោងសរុប ដុល្លារអាមេរិក | តម្លៃយោងសរុប ពាន់រៀល (កំណត់សម្គាល់ 5) |
|---|---|---|---|---|---|---|
| **ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022** | | | | | | |
| **បំណុលហិរញ្ញវត្ថុ** | | | | | | |
| ប្រាក់កម្ចី | - | - | 15,341,077 | - | 15,341,077 | 63,159,214 |
| អនុបំណុល | - | - | 2,202,043 | - | 2,202,043 | 9,065,811 |
| បំណុលផ្សេងៗ | - | - | 143,680 | - | 143,680 | 591,531 |
| **បំណុលហិរញ្ញវត្ថុសរុប** | - | - | 17,686,800 | - | 17,686,800 | 72,816,556 |

## 26. ចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

តារាងខាងក្រោម បង្ហាញការផ្ទៀងផ្ទាត់រវាងធាតុនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងចំណាត់ថ្នាក់នៃឧបករណ៍ហិរញ្ញវត្ថុ។ (ត)

| | តម្លៃសមស្របតាម ចំណេញ ឬខាត | តម្លៃសមស្របតាម លទ្ធផលលម្អិតផ្សេងៗ | តាម រំលស់ថ្លៃដើម | ដក ឱនភាពនៃតម្លៃ | តម្លៃយោងសរុប | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021** | | | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | |
| សាច់ប្រាក់ក្នុងដៃ | - | - | 192,475 | - | 192,475 | 784,143 |
| សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា | - | - | 630,550 | - | 630,550 | 2,568,861 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | - | - | 328,394 | - | 328,394 | 1,337,877 |
| ឥណទានផ្តល់ដល់អតិថិជន | - | - | 15,568,378 | (365,335) | 15,203,043 | 61,937,197 |
| ទ្រព្យសកម្មផ្សេងៗ | - | - | 96,018 | - | 96,018 | 391,178 |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | - | - | 16,815,815 | (365,335) | 16,450,480 | 67,019,256 |

## 26. ចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

តារាងខាងក្រោម បង្ហាញការផ្ទៀងផ្ទាត់រវាងធាតុនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងចំណាត់ថ្នាក់នៃឧបករណ៍ហិរញ្ញវត្ថុ។ (ត)

| | តម្លៃសមស្របតាម ចំណេញ ឬខាត | តម្លៃសមស្របតាម លទ្ធផលលម្អិតផ្សេងៗ | តាម រំលស់ថ្លៃដើម | ដក ឱនភាពនៃតម្លៃ | តម្លៃយោងសរុប | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| **ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021** | | | | | | |
| **បំណុលហិរញ្ញវត្ថុ** | | | | | | |
| ប្រាក់កម្ចី | - | - | 9,477,204 | - | 9,477,204 | 38,610,129 |
| បំណុលផ្សេងៗ | - | - | 63,930 | - | 63,930 | 260,451 |
| **បំណុលហិរញ្ញវត្ថុសរុប** | - | - | 9,541,134 | - | 9,541,134 | 38,870,580 |

## 27. កិច្ចសន្យា និងយថាភាព

### ក. កិច្ចសន្យាភតិសន្យា

ក្រុមហ៊ុន មានកិច្ចសន្យាទាក់ទិននឹងកិច្ចព្រមព្រៀងភតិសន្យាប្រតិបត្តិការលើការជួលការិយាល័យកណ្តាល និងសាខា ជាមួយចំនួនភតិសន្យាអប្បបរមានាពេលអនាគតមានដូចខាងក្រោម៖

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2021 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| រយៈពេល 1ឆ្នាំ | 201,523 | 829,670 | 87,317 | 355,204 |
| រយៈពេល 1 ទៅ 5ឆ្នាំ | 636,571 | 2,620,763 | 28,000 | 113,904 |
| លើសពី 5ឆ្នាំ | 48,333 | 198,987 | - | - |
| | 886,427 | 3,649,420 | 115,317 | 469,108 |

### ខ. យថាភាពលើពន្ធ

នៅថ្ងៃទី12 ខែមេសា ឆ្នាំ2022 អគ្គនាយកដ្ឋានពន្ធដារ ("អ.ព.ដ") បានចេញលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញលើសវនកម្មពន្ធមានកម្រិត សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2018 ដល់ថ្ងៃទី31 ខែសីហា ឆ្នាំ2019 លើបំណុលពន្ធ រួមទាំងការផាកពិន័យ និងការប្រាក់ចំនួន 24,419,027 រៀល សមមូលនឹង 5,939 ដុល្លារអាមេរិក។ ចំនួននៃការកំណត់ពន្ធឡើងវិញត្រូវបានទូទាត់គ្រប់ នៅថ្ងៃទី10 ខែឧសភា ឆ្នាំ2022។

នៅថ្ងៃទី21 ខែមេសា ឆ្នាំ2022 អគ្គនាយកដ្ឋានពន្ធដារ ("អ.ព.ដ") បានចេញលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញលើសវនកម្មពន្ធពេញលេញ សម្រាប់ការិយបរិច្ឆេទចាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2018 ដល់ថ្ងៃទី31 ខែសីហា ឆ្នាំ2019 លើបំណុលពន្ធ រួមទាំងការផាកពិន័យ និងការប្រាក់ចំនួន 158,548,556 រៀល សមមូលនឹង 38,490 ដុល្លារអាមេរិក។ នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 បំណុលពន្ធត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ (កំណត់សម្គាល់ 15) និងបន្ទាប់មក ក្រុមហ៊ុនបានទូទាត់បំណុលពន្ធខាងលើដល់ អ.ព.ដ នៅថ្ងៃទី21 ខែកុម្ភៈ ឆ្នាំ2023។

ការប្រកាសពន្ធរបស់ក្រុមហ៊ុន ត្រូវមានការត្រួតពិនិត្យដោយអាជ្ញាធរពន្ធដារទៅតាមការិយបរិច្ឆេទ។ ដោយសារផ្នែកខ្លះនៃច្បាប់ និងបទប្បញ្ញត្តិពន្ធដារអាចមានបំណកស្រាយខុសៗគ្នា ចំនួនពន្ធដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនអាចមានការផ្លាស់ប្តូរនៅពេលក្រោយ អាស្រ័យលើការកំណត់ចុងក្រោយដោយអាជ្ញាធរពន្ធដារ។

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

### 28. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗ ដែលបានបង្ហាញនៅខាងក្រោមនេះ ត្រូវបានអនុវត្តដោយសង្គតិភាពនៅគ្រប់ការិយបរិច្ឆេទដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ លើកលែងតែមានការបង្ហាញផ្សេងពីនេះ។

### ក. ប្រតិបត្តិការជារូបិយប័ណ្ណបរទេស

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើប្រាស់អត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ។

ទ្រព្យសកម្មរូបិយវត្ថុ និងបំណុលរូបិយវត្ថុនាកាលបរិច្ឆេទរាយការណ៍ដែលជារូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិកដោយប្រើអត្រានាកាលបរិច្ឆេទរាយការណ៍។ ធាតុមិនមែនរូបិយវត្ថុដែលត្រូវបានវាស់វែងផ្អែកលើថ្លៃដើមប្រវត្តិសាស្ត្រជារូបិយប័ណ្ណបរទេសផ្សេងទៀត ត្រូវបានប្តូរដោយប្រើប្រាស់អត្រាប្តូរប្រាក់នៅកាលបរិច្ឆេទនៃប្រតិបត្តិការដំបូង។ ភាពលម្អៀងពីការប្តូររូបិយប័ណ្ណ ជាទូទៅ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។

### ខ. ឧបករណ៍ហិរញ្ញវត្ថុ

#### *(i). ការទទួលស្គាល់*

ក្រុមហ៊ុនទទួលស្គាល់ជាលើកដំបូងនូវទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ នៅពេលដែលក្រុមហ៊ុនក្លាយជាភាគីនៃកិច្ចសន្យាឧបករណ៍ហិរញ្ញវត្ថុ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប បូកនឹងថ្លៃដើមប្រតិបត្តិការដែលកើតមកពីការទិញ ឬបោះផ្សាយទ្រព្យសកម្ម និងបំណុលទាំងនោះ។

#### *(ii). ការចាត់ចំណាត់ថ្នាក់*

ក្រុមហ៊ុនចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ជាឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន ស្របទៅតាមផ្នែកទី11 *ឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន*។

#### *(iii). ការឈប់ទទួលស្គាល់*

ក្រុមហ៊ុន ឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិទទួលបានលំហូរទឹកប្រាក់តាមកិច្ចសន្យានៃទ្រព្យសកម្មនោះផុតកំណត់ ឬបានទូទាត់ ឬក្រុមហ៊ុន បានផ្ទេរសិទ្ធិក្នុងការទទួលបានលំហូរទឹកប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការដែលរាល់ហានិភ័យ និងអត្ថប្រយោជន៍នៃភាពជាកម្មសិទ្ធិទាំងអស់នៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានផ្ទេរ ឬក្នុងករណីដែលក្រុមហ៊ុនមិនផ្ទេរ ឬមិនរក្សាទុកនូវរាល់ហានិភ័យ និងអត្ថប្រយោជន៍នៃភាពជាកម្មសិទ្ធិ ហើយក្រុមហ៊ុនមិនរក្សាការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

ក្រុមហ៊ុនឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលកាតព្វកិច្ចក្រោមកិច្ចសន្យាត្រូវបានរំលាយ ឬលុបចោល ឬផុតអាណត្តិ។

## ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

### កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
### សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

### 28. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ខ. ឧបករណ៍ហិរញ្ញវត្ថុ (ត)

*(iv). ការកាត់កង*

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ អាចត្រូវកាត់កងគ្នាបាន និងត្រូវបានបង្ហាញជាចំនួនសុទ្ធនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លុះត្រាតែក្រុមហ៊ុនមានសិទ្ធិតាមច្បាប់ដើម្បីធ្វើការកាត់កងគ្នាបាន និងមានបំណងធ្វើការទូទាត់ដោយផ្អែកលើមូលដ្ឋានចំនួននៅសល់សុទ្ធ ឬក៏ទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

*(v). ការវាស់វែងរំលស់ថ្លៃដើម*

រំលស់ថ្លៃដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ គឺជាចំនួនទឹកប្រាក់ដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងនៅពេលទទួលស្គាល់ជាលើកដំបូង ដកការទូទាត់ប្រាក់ដើម និងបូក ឬដករំលស់បង្គរដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព នៃភាពខុសគ្នារវាងចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ដំបូង និងពេលដល់កាលកំណត់ ដកឱនភាពនៃតម្លៃ។

*(vi). ការវាស់វែងតម្លៃសមស្រប*

តម្លៃសមស្រប គឺជាតម្លៃដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្ម ឬតម្លៃដែលបានទូទាត់ចំពោះការផ្ទេរបំណុលនៅក្នុងប្រតិបត្តិការធម្មតា រវាងអ្នកចូលរួមក្នុងទីផ្សារ នាកាលបរិច្ឆេទនៃការវាស់វែង នៅក្នុងទីផ្សារគោល ឬក្នុងករណីមិនមានទីផ្សារគោល គឺយកទីផ្សារដែលមានអត្ថប្រយោជន៍បំផុត ដែលក្រុមហ៊ុនអាចកំណត់រកបាននៅកាលបរិច្ឆេទនៃការវាស់វែងនោះ។ តម្លៃសមស្របរបស់បំណុល ឆ្លុះបញ្ចាំងពីហានិភ័យនៃការមិនអនុវត្តកាតព្វកិច្ច។

ក្រុមហ៊ុនវាស់វែងតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ ដោយប្រើសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មរបស់ឧបករណ៍នោះ ប្រសិនបើមាន។ ទីផ្សារមួយចាត់ទុកជាទីផ្សារសកម្ម ប្រសិនបើប្រតិបត្តិការរបស់ទ្រព្យសកម្ម ឬបំណុល កើតឡើងញឹកញាប់ ហើយទំហំប្រតិបត្តិការមានភាពគ្រប់គ្រាន់ក្នុងការផ្តល់ព័ត៌មានតម្លៃជាទៀងទាត់។

ប្រសិនបើពុំមានសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មទេ នោះក្រុមហ៊ុនត្រូវប្រើបច្ចេកទេសវាយតម្លៃណាដែលអាចប្រើប្រាស់ទិន្នន័យដែលអាចអង្កេតបានជាអតិបរមា និងកាត់បន្ថយនូវការប្រើប្រាស់ទិន្នន័យដែលមិនអាចអង្កេតបាន។ បច្ចេកទេសវាយតម្លៃដែលបានជ្រើសរើស ត្រូវរួមបញ្ចូលនូវកត្តាទាំងអស់ដែលអ្នកចូលរួមក្នុងទីផ្សារនឹងពិចារណានៅក្នុងការកំណត់តម្លៃ។

## 28. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ខ. ឧបករណ៍ហិរញ្ញវត្ថុ (ត)

*(vi). ការវាស់វែងតម្លៃសមស្រប (ត)*

ភស្តុតាងដ៏ល្អបំផុតសម្រាប់តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ នៅពេលទទួលស្គាល់ជាលើកដំបូង ជាទូទៅគឺជាតម្លៃប្រតិបត្តិការ មានន័យថា ជាតម្លៃសមស្របនៃផលតបស្នងបានផ្តល់ឲ្យ ឬបានទទួល។ ប្រសិនបើ ក្រុមហ៊ុនកំណត់ថា តម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង ខុសពីតម្លៃប្រតិបត្តិការ ហើយតម្លៃសមស្របនេះពុំមានភស្តុតាងមកបញ្ជាក់ តាមរយៈសម្រង់តម្លៃក្នុងទីផ្សារសកម្មចំពោះទ្រព្យសកម្ម ឬបំណុលដែលស្រដៀងគ្នា ឬក៏តាមរយៈបច្ចេកទេសវាយតម្លៃ ដោយប្រើប្រាស់តែទិន្នន័យទីផ្សារដែលអាចអង្កេតបាន ដូច្នេះឧបករណ៍ហិរញ្ញវត្ថុត្រូវវាស់វែងជាលើកដំបូងតាមតម្លៃសមស្រប ដោយកែតម្រូវតាមរយៈការពន្យារនូវភាពខុសគ្នារវាងតម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង និងតម្លៃប្រតិបត្តិការ។ នាពេលបន្តបន្ទាប់ ភាពខុសគ្នានោះគឺត្រូវទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត ផ្អែកលើមូលដ្ឋានសមរម្យទៅតាមអាយុកាលរបស់ឧបករណ៍នោះ ក៏ប៉ុន្តែមិនឲ្យយូរជាងការវាយតម្លៃតាមរយៈទិន្នន័យទីផ្សារដែលអាចអង្កេតបាន ឬនៅពេលបញ្ចប់ប្រតិបត្តិការនោះទេ។

ក្រុមហ៊ុនទទួលស្គាល់ការផ្ទេររវាងកម្រិតនៃឋានានុក្រមតម្លៃសមស្រប នៅចុងការិយបរិច្ឆេទរាយការណ៍អំឡុងពេលដែលការផ្លាស់ប្តូរបានកើតឡើង។

***(vii). ការកំណត់អត្តសញ្ញាណ និងការវាស់វែងឱនភាពនៃតម្លៃ***

*ភស្តុតាងដែលបញ្ជាក់ថាមានឱនភាពនៃតម្លៃ*

នៅកាលបរិច្ឆេទរាយការណ៍នីមួយៗ ក្រុមហ៊ុនវាយតម្លៃថាតើមានភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកត់ត្រាតាមថ្លៃដើម ឬរំលស់ថ្លៃដើម។ ទ្រព្យសកម្មហិរញ្ញវត្ថុ ឬក្រុមនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃ នៅពេលដែលមានភស្តុតាងបញ្ជាក់ថា មានព្រឹត្តិការណ៍ខាតបង់មួយ ឬច្រើនបានកើតឡើងបន្ទាប់ពីការទទួលស្គាល់ទ្រព្យសកម្មជាលើកដំបូង ហើយដែលនាំឲ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើលំហូរទឹកប្រាក់នាពេលអនាគតនៃទ្រព្យសកម្ម ដែលអាចប៉ាន់ស្មានដោយភាពជឿជាក់បាន។

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពនៃតម្លៃ រួមមាន៖

- ការលំបាកផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំងរបស់អតិថិជន ឬអ្នកបោះផ្សាយ
- ការខកខានមិនបានសង ឬហួសកាលកំណត់សងរបស់អតិថិជន
- ការរៀបចំឡើងវិញលើលក្ខខណ្ឌនៃឥណទាន ឬបុរេប្រទាន ដែលក្រុមហ៊ុនមិនបានពិចារណា

## 28. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ខ. ឧបករណ៍ហិរញ្ញវត្ថុ (ត)

#### *(vii). ការកំណត់អត្តសញ្ញាណ និងការវាស់វែងឱនភាពនៃតម្លៃ (ត)*

*ភស្តុតាងដែលបញ្ជាក់ថាមានឱនភាពនៃតម្លៃ (ត)*

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពនៃតម្លៃរួមមាន៖ (ត)

- សញ្ញាណដែលបញ្ជាក់ថាអតិថិជន ឬអ្នកបោះផ្សាយ ទំនងនឹងជួបប្រទះការក្ស័យធន
- ការបាត់បង់ទីផ្សារសកម្មសម្រាប់មូលប័ត្រ ឬ
- ទិន្នន័យដែលអាចអង្កេតបានពាក់ព័ន្ធនឹងក្រុមនៃទ្រព្យសកម្ម ដូចជាការផ្លាស់ប្តូរអវិជ្ជមានក្នុងស្ថានភាពនៃការទូទាត់របស់អតិថិជន ឬអ្នកបោះផ្សាយជាក្រុម ឬលក្ខខណ្ឌសេដ្ឋកិច្ចដែលទាក់ទងនឹងការខកខានមិនបានសងជាក្រុម។

*ការវាយតម្លៃជាលក្ខណៈទោល និងជាក្រុម*

រាល់ទ្រព្យសកម្មដែលមានលក្ខណៈទោលជាសារវន្ត ត្រូវបានវាយតម្លៃជាលក្ខណៈទោលសម្រាប់ឱនភាពនៃតម្លៃ។

ការវាយតម្លៃជាលក្ខណៈទោលដែលត្រូវបានរកឃើញថាមិនមានឱនភាពនៃតម្លៃជាពិសេស ត្រូវបានវាយតម្លៃជាក្រុមសម្រាប់ឱនភាពនៃតម្លៃដែលបានកើតឡើង ប៉ុន្តែមិនទាន់ទទួលស្គាល់នៅឡើយ។

សមាសធាតុទោលនៃសំវិធានធនសរុបសម្រាប់ឱនភាពនៃតម្លៃ ត្រូវបានអនុវត្តចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាយតម្លៃជាលក្ខណៈទោលនៃឱនភាពនៃតម្លៃ ហើយត្រូវបានរកឃើញថាមានឱនភាពនៃតម្លៃទោល និងផ្អែកតាមការប៉ាន់ស្មានដ៏ប្រសើរបំផុតរបស់អ្នកគ្រប់គ្រងលើតម្លៃបច្ចុប្បន្ននៃលំហូរទឹកប្រាក់ ដែលរំពឹងថានឹងទទួលបាន។ ក្នុងការប៉ាន់ស្មានលំហូរទឹកប្រាក់ទាំងនេះ អ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យអំពីស្ថានភាពហិរញ្ញវត្ថុរបស់កូនបំណុល និងតម្លៃសុទ្ធដែលអាចលក់បានចំពោះទ្រព្យបញ្ចាំណាមួយ។ ទ្រព្យសកម្មដែលមានឱនភាពនៃតម្លៃនីមួយៗ ត្រូវបានវាយតម្លៃលើគុណសម្បត្តិរបស់វា ហើយយុទ្ធសាស្ត្រគណនា និងការប៉ាន់ស្មានលំហូរទឹកប្រាក់ដែលអាចប្រមូលបានមកវិញ ត្រូវបានអនុម័តឯករាជ្យដោយអ្នកគ្រប់គ្រង។

សមាសធាតុជាក្រុមនៃសំវិធានធនសរុបត្រូវបានបង្កើតឡើងសម្រាប់៖

- ក្រុមនៃឥណទានដែលមានលក្ខណៈដូចគ្នា ហើយមិនត្រូវបានចាត់ទុកថាជាលក្ខណៈទោលសារវន្ត និង
- ក្រុមនៃទ្រព្យសកម្មដែលមានលក្ខណៈទោលជាសារវន្ត ប៉ុន្តែមិនត្រូវបានរកឃើញថាមានឱនភាពនៃតម្លៃទោលនោះទេ។

## 28. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ខ. ឧបករណ៍ហិរញ្ញវត្ថុ (ត)

*(vii). ការកំណត់អត្តសញ្ញាណ និងការវាស់វែងឱនភាពនៃតម្លៃ (ត)*

*ការវាយតម្លៃជាលក្ខណៈទោល និងជាក្រុម (ត)*

សំវិធានធនជាក្រុម សម្រាប់ក្រុមនៃឥណទានត្រូវទទួលមានលក្ខណៈដូចគ្នា ត្រូវបានបង្កើតឡើងដោយប្រើវិធីសាស្រ្តស្ថិតិ ដូចជាវិធីសាស្រ្តអត្រាវិលជុំ ឬសម្រាប់ផលប័ត្រតូចៗដែលមិនមានព័ត៌មានគ្រប់គ្រាន់វិធីសាស្រ្តផ្អែកលើបទពិសោធន៍អត្រាបាត់បង់ប្រវត្តិសាស្រ្ត។

ក្នុងការវាយតម្លៃសំវិធានធនលើការខាតបង់ជាក្រុម អ្នកគ្រប់គ្រងបានពិចារណាលើកត្តាមួយចំនួនដូចជាគុណភាពឥណទាន ទំហំផលប័ត្រ ការប្រមូលផ្តុំ និងកត្តាសេដ្ឋកិច្ចជាដើម។ ដើម្បីប៉ាន់ប្រមាណនូវតម្រូវការសំវិធានធន ការសន្មតត្រូវបានធ្វើឡើងដើម្បីកំណត់ពីលក្ខណៈនៃការខាតបង់ ដែលត្រូវបានយកគំរូតាម និងការកំណត់ទិន្នន័យប៉ារ៉ាម៉ែត្រតាមតម្រូវការ ដោយផ្អែកលើបទពិសោធន៍ប្រវត្តិសាស្រ្ត និងស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន។ ភាពត្រឹមត្រូវនៃសំវិធានធន អាស្រ័យលើការសន្មតនូវគំរូ និងប៉ារ៉ាម៉ែត្រដែលត្រូវបានប្រើប្រាស់ក្នុងការកំណត់សំវិធានធនជាក្រុម។

*ការវាស់វែង*

ការខាតបង់ឱនភាពនៃតម្លៃលើទ្រព្យសកម្មដែលបានវាស់វែងតាមរំលស់ថ្លៃដើម ត្រូវបានគណនាដោយភាពខុសគ្នារវាងតម្លៃយោង និងតម្លៃបច្ចុប្បន្ននៃលំហូរទឹកប្រាក់ដែលបានប៉ាន់ស្មាននាពេលអនាគត ដែលបានធ្វើអប្បហារតាមអត្រាការប្រាក់ប្រសិទ្ធភាពដើមរបស់ទ្រព្យសកម្ម។

*ការទទួលបានមកវិញ និងការលុបចោលឱនភាពនៃតម្លៃ*

ប្រសិនបើក្នុងរយៈពេលបន្ទាប់ ចំនួននៃការខាតបង់លើឱនភាពនៃតម្លៃមានការថយចុះ ហើយការថយចុះនោះអាចទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលកើតឡើងបន្ទាប់ពីឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់ ក្រុមហ៊ុនត្រូវធ្វើការកែប្រែលើការខាតបង់ឱនភាពនៃតម្លៃដែលបានទទួលស្គាល់ពីមុនដោយផ្ទាល់ ឬដោយការធ្វើនិយ័តភាពចំពោះគណនីសំវិធានធន។

ការទទួលបានមកវិញ នឹងមិនបណ្តាលឲ្យមានចំនួនតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ (ក្រោយកាត់កងគណនីសំវិធានធន) លើសពីចំនួនតម្លៃយោងដែលមានឱនភាពនៃតម្លៃ ដែលមិនបានទទួលស្គាល់ពីមុននោះទេ។ ក្រុមហ៊ុន ត្រូវទទួលស្គាល់ចំនួនទឹកប្រាក់ដែលទទួលបានមកវិញ ក្នុងរបាយការណ៍ចំណេញ ឬខាតភ្លាមៗ។

ក្រុមហ៊ុន លុបចោលឥណទានផ្នែកខ្លះ ឬទាំងស្រុង និងសំវិធានធនពាក់ព័ន្ធ សម្រាប់ការខាតបង់លើឱនភាពនៃតម្លៃ នៅពេលដែលអ្នកគ្រប់គ្រងកំណត់ថាមិនមានលទ្ធភាពជាក់លាក់ក្នុងការប្រមូលបានមកវិញ។

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

### 28. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### គ. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ និងសមតុល្យនៅធនាគារ ប្រាក់បញ្ញើ និងការវិនិយោគរយៈពេលខ្លី ដែលមានកាលវសាននៅពេលតម្កល់ដំបូងមានរយៈពេល 3ខែ ឬតិចជាង ដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បាន ដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ និងត្រូវបានប្រើប្រាស់ដោយក្រុមហ៊ុនក្នុងការគ្រប់គ្រងកិច្ចសន្យារយៈពេលខ្លីរបស់ខ្លួន។

សាច់ប្រាក់ និងសាច់ប្រាក់សមមូល ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើមដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

### ឃ. សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា

ប្រាក់តម្កល់នៅធនាគារ ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើមដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

### ង. ប្រាក់តម្កល់តាមច្បាប់

ប្រាក់តម្កល់តាមច្បាប់ សំដៅលើប្រាក់តម្កល់ធានាលើដើមទុនដែលត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជាដោយអនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានកំណត់ជាភាគរយនៃដើមទុនអប្បបរមា ដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។ ប្រាក់តម្កល់តាមច្បាប់មិនអាចប្រើប្រាស់ជាហិរញ្ញប្បទាន សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុនទេ ដូច្នេះវាមិនត្រូវបានចាត់ទុកជាផ្នែកមួយនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូលសម្រាប់គោលបំណងនៃរបាយការណ៍លំហូរទឹកប្រាក់ឡើយ។

ប្រាក់តម្កល់តាមច្បាប់ ត្រូវបានកត់ត្រាតាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

### ច. ឥណទានផ្តល់ដល់អតិថិជន

ឥណទានផ្តល់ដល់អតិថិជន គឺជាទ្រព្យសកម្មហិរញ្ញវត្ថុអនិស្សន្ទដែលអាចទូទាត់បានតាមលក្ខណៈថេរ ឬអាចកំណត់បាន ដែលមិនមែនជាសម្រង់តម្លៃពីទីផ្សារសកម្ម ហើយក្រុមហ៊ុនមិនមានបំណងលក់នៅក្នុងពេលបច្ចុប្បន្ន ឬនៅពេលខាងមុខនោះទេ។

ឥណទានផ្តល់ដល់អតិថិជន ត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្រប បូកចំណាយប្រតិបត្តិការដែលកើតឡើងដោយផ្ទាល់ ហើយនាពេលបន្ទាប់ ត្រូវកត់ត្រាតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

### 28. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ឆ. ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗទៀត ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

### ជ. ទ្រព្យ និងបរិក្ខារ

ផ្នែកនៃទ្រព្យ និងបរិក្ខារ ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់ឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន។ នៅពេលដែលផ្នែកនៃទ្រព្យ និងបរិក្ខារ មានអាយុកាលប្រើប្រាស់ខុសៗគ្នា ផ្នែកទាំងនោះត្រូវបានចាត់ទុកជាផ្នែកផ្សេងគ្នានៃទ្រព្យ និងបរិក្ខារ។

រំលស់លើទ្រព្យ និងបរិក្ខារ ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងរបាយការណ៍ចំណេញ ឬខាតលើមូលដ្ឋានរំលស់ថេរតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យសកម្មនីមួយៗ ដូចខាងក្រោម៖

| | អាយុកាលប្រើប្រាស់ |
|---|---|
| ការកែលម្អទ្រព្យជួល | 4ឆ្នាំ |
| បរិក្ខារការិយាល័យ | 4ឆ្នាំ |
| បរិក្ខារកុំព្យូទ័រ និងព័ត៌មានវិទ្យា | 4ឆ្នាំ |
| យានយន្ត | 4ឆ្នាំ |

ចំណាយបន្តបន្ទាប់ដែលពាក់ព័ន្ធទៅនឹងផ្នែកមួយនៃទ្រព្យ និងបរិក្ខារ ដែលបានទទួលស្គាល់រួចមកហើយ ត្រូវបានបូកបញ្ចូលទៅក្នុងតម្លៃយោងនៃផ្នែកនោះ ប្រសិនបើអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់ក្រុមហ៊ុនលើសពីស្តង់ដាដើម។ រាល់ចំណាយបន្តបន្ទាប់ផ្សេងៗទៀត ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងការិយបរិច្ឆេទដែលបានកើតឡើង។

ចំណេញ ឬខាតពីការឈប់ប្រើប្រាស់ ឬការលក់ចេញផ្នែកនៃទ្រព្យ និងបរិក្ខារណាមួយត្រូវបានកំណត់ដោយភាពខុសគ្នារវាងសាច់ប្រាក់ទទួលបានពីការលក់ និងតម្លៃយោងនៃផ្នែកនោះ ហើយត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត នៅពេលដែលឈប់ប្រើប្រាស់ ឬលក់ចេញ។

ទ្រព្យ និងបរិក្ខារ ដែលបានដករំលស់អស់ហើយ ត្រូវបានរក្សាទុកក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់ពេលដែលទ្រព្យ និងបរិក្ខារទាំងនោះត្រូវបានលក់ចេញ ឬលុបចោល។

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

## 28. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ឈ. ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី ដែលរួមមានកុំព្យូទ័រសូហ្វវែរ ត្រូវបានវាស់វែងតាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់ឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន។ ទ្រព្យសកម្មអរូបី ត្រូវបានរំលស់តាមអត្រា 25% ក្នុងមួយឆ្នាំ ឬផ្អែកតាមកិច្ចសន្យារួមគ្នាដែលមានអាយុកាលជាក់លាក់ និងតាមអត្រា 10% ក្នុងមួយឆ្នាំ សម្រាប់កិច្ចសន្យាដែលមិនមានអាយុកាលជាក់លាក់ ដោយប្រើប្រាស់វិធីសាស្ត្ររំលស់ថេរ។

ថ្លៃដើមដែលបានកើតឡើងក្នុងការរៀបចំផែនការ ឬវាយតម្លៃសំណើសូហ្វវែរ ឬក្នុងការថែទាំប្រព័ន្ធបន្ទាប់ពីដាក់ឲ្យដំណើរការ មិនត្រូវបានទទួលស្គាល់ទេ។

វិធីសាស្ត្ររំលស់ អាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់ ត្រូវបានវាយតម្លៃនៅរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ និងធ្វើនិយ័តភាពប្រសិនបើសមស្រប។

### ញ. ឱនភាពនៃតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យនៃសកម្មមិនមែនហិរញ្ញវត្ថុរបស់ក្រុមហ៊ុន (ក្រៅពីពន្ធពន្យារជាទ្រព្យសកម្ម) ត្រូវបានត្រួតពិនិត្យឡើងវិញនៅរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានសញ្ញាណណាមួយដែលបង្ហាញថាទ្រព្យសកម្មទាំងនោះមានឱនភាពនៃតម្លៃ។ ប្រសិនបើមានសញ្ញាណនោះកើតឡើង ការប៉ាន់ស្មានលើតម្លៃដែលអាចប្រមូលបានមកវិញរបស់ទ្រព្យសកម្មត្រូវបានធ្វើឡើង។

តម្លៃដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺជាតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃសមស្រប ដកចំណាយដើម្បីលក់ចេញ។ ក្នុងការប៉ាន់ប្រមាណតម្លៃប្រើប្រាស់ ការប៉ាន់ស្មានលំហូរទឹកប្រាក់នាពេលអនាគត ត្រូវបានធ្វើអប្បហារមកតម្លៃបច្ចុប្បន្ន ដោយប្រើអត្រាការប្រាក់មុនបង់ពន្ធដែលឆ្លុះបញ្ចាំងការប៉ាន់ប្រមាណតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់សម្រាប់ទ្រព្យសកម្មទាំងនោះ។ សម្រាប់គោលបំណងនៃការធ្វើតេស្តលើឱនភាពនៃតម្លៃ ទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុមតូចៗ ដែលអាចបង្កើតសាច់ប្រាក់បានពីការបន្តការប្រើប្រាស់ ដោយមិនពឹងផ្អែកខ្លាំងលើលំហូរទឹកប្រាក់នៃទ្រព្យសកម្មផ្សេងៗ ឬក្រុមនៃទ្រព្យសកម្ម ("ឯកតាបង្កើតសាច់ប្រាក់")។

ការខាតបង់ឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងរបស់ទ្រព្យសកម្មមួយ ឬឯកតាបង្កើតសាច់ប្រាក់ មានចំនួនលើសពីតម្លៃដែលប៉ាន់ស្មានថាអាចប្រមូលមកបានវិញ។ ការខាតបង់ឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់ជាក្នុងរបាយការណ៍ចំណេញ ឬខាត។

## 28. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ដ. ប្រាក់កម្ចី អនុបំណុល និងបំណុលផ្សេងៗ

ប្រាក់កម្ចី អនុបំណុល និងបំណុលផ្សេងៗ ត្រូវបានកត់ត្រាតាមរំលស់ថ្លៃដើម ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

### ឋ. សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយវាមានលទ្ធភាពដែលតម្រូវឲ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងការបំពេញនូវកាតព្វកិច្ចនោះ។ ប្រសិនបើផលប៉ះពាល់មានលក្ខណៈជាសារវន្ត សំវិធានធនត្រូវបានកំណត់ដោយអប្បហារលំហូរទឹកប្រាក់ដែលរំពឹងថានឹងត្រូវទូទាត់នាពេលអនាគត ដោយប្រើអត្រាមុនបង់ពន្ធដែលឆ្លុះបញ្ចាំងពីការប៉ាន់ស្មាននៃតម្លៃពេលវេលា ក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ។ អប្បហារនៅសល់ត្រូវបានទទួលស្គាល់ជាចំណាយហិរញ្ញប្បទាន។

### ឌ. អត្ថប្រយោជន៍និយោជិត

#### *(i). អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី*

អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី ត្រូវបានចំណាយនៅពេលដែលសេវាកម្មត្រូវបានផ្តល់ជូន។ ចំនួនដែលរំពឹងទុកថានឹងត្រូវចំណាយ ត្រូវបានទទួលស្គាល់ជាបំណុល ប្រសិនបើក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ក្នុងការទូទាត់ចំណាយ ដែលជាលទ្ធផលនៃការងារដែលបានបំពេញរួចមកហើយដោយនិយោជិត ហើយកាតព្វកិច្ចនោះអាចធ្វើការប៉ាន់ស្មានបានដោយភាពជឿជាក់។

#### *(ii). អត្ថប្រយោជន៍និយោជិតរយៈពេលវែង*

កាតព្វកិច្ចសុទ្ធរបស់ក្រុមហ៊ុន ទាក់ទងនឹងអត្ថប្រយោជន៍រយៈពេលវែងរបស់បុគ្គលិកគឺ ចំនួនទឹកប្រាក់នៃអត្ថប្រយោជន៍ដែលបុគ្គលិកទទួលបានពីការផ្តល់សេវាកម្មរបស់ខ្លួន ក្នុងអំឡុងពេលបច្ចុប្បន្ន និងរយៈពេលមុនៗ។ អត្ថប្រយោជន៍នេះ ត្រូវបានធ្វើអប្បហារដើម្បីកំណត់តម្លៃបច្ចុប្បន្ន។ ការវាស់វែងឡើងវិញត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលលម្អិតក្នុងអំឡុងពេលដែលបានកើតឡើង។

# ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

## 28. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ឍ. ដើមទុន

ថ្លៃដើមផ្ទាល់ដែលទាក់ទងនឹងការបោះផ្សាយឧបករណ៍មូលធន ត្រូវបានទទួលស្គាល់ជាការកាត់កងចេញពីឧបករណ៍មូលធនដែលបានវាស់វែងលើកដំបូង។

### ណ. ទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងតាមបទប្បញ្ញត្តិ ត្រូវបានបង្កើតឡើងសម្រាប់ភាពខុសគ្នានៃសំវិធានធន រវាងឥណទានមានឱនភាពនៃតម្លៃ ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម និងសំវិធានធនតាមបទប្បញ្ញត្តិស្របតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ7-017-344 ចុះថ្ងៃទី1 ខែធ្នូ ឆ្នាំ2017 និងសារាចរណែនាំ លេខ ធ7-018-001 ស.រ.ច.ណ ចុះថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ2018 ស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើឱនភាពនៃតម្លៃ សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

យោងតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា រាល់ឥណទានផ្តល់ដល់អតិថិជន ត្រូវធ្វើចំណាត់ថ្នាក់តាមសមត្ថភាពសងរបស់អ្នកខ្ចី និងចំនួនថ្ងៃដែលហួសកំណត់ដូចខាងក្រោម៖

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃដែលហួសកាលកំណត់សង | អត្រាសំវិធានធន |
|---|---|---|
| **ឥណទានរយៈពេលខ្លី (តិចជាង ឬស្មើមួយឆ្នាំ)៖** | | |
| ឥណទានធម្មតា/ស្តង់ដា | <15ថ្ងៃ | 1% |
| ឥណទានឃ្លាំមើល | 15ថ្ងៃ ដល់ 30ថ្ងៃ | 3% |
| ឥណទានក្រោមស្តង់ដា | 31ថ្ងៃ ដល់ 60ថ្ងៃ | 20% |
| ឥណទានជាប់សង្ស័យ | 61ថ្ងៃ ដល់ 90ថ្ងៃ | 50% |
| ឥណទានបាត់បង់ | ≥91ថ្ងៃ | 100% |
| **ឥណទានរយៈពេលវែង (ច្រើនជាងមួយឆ្នាំ)៖** | | |
| ឥណទានធម្មតា/ស្តង់ដា | <30ថ្ងៃ | 1% |
| ឥណទានឃ្លាំមើល | ≥30ថ្ងៃ ដល់ 89ថ្ងៃ | 3% |
| ឥណទានក្រោមស្តង់ដា | ≥90ថ្ងៃ ដល់ 179ថ្ងៃ | 20% |
| ឥណទានជាប់សង្ស័យ | ≥180ថ្ងៃ ដល់ 359ថ្ងៃ | 50% |
| ឥណទានបាត់បង់ | ច្រើនជាង 359ថ្ងៃ | 100% |

## 27. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ណ. ទុនបម្រុងតាមបទប្បញ្ញត្តិ (ត)

ដោយអនុលោមតាមប្រកាស ក្រុមហ៊ុនត្រូវប្រៀបធៀបសំវិធានធន ដែលគណនាតាមតម្រូវការខាងលើ ជាមួយនឹងសំវិធានធន ដែលគណនាតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យមៈ

(i) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិទាបជាង នោះក្រុមហ៊ុនត្រូវកត់ត្រាសំវិធានធន អនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម និង

(ii) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិខ្ពស់ជាង នោះក្រុមហ៊ុនត្រូវកត់ត្រាសំវិធានធន ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម និងផ្ទេរចំនួនលម្អៀងនោះពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ នៅក្នុងគណនីមូលធន។

ទុនបម្រុងតាមបទប្បញ្ញត្តិ មិនមែនជាផ្នែកដែលត្រូវបានរួមបញ្ចូលក្នុងការគណនានៃទ្រព្យសកម្មរបស់ក្រុមហ៊ុនឡើយ។

### ត. ការប្រាក់

ចំណូលពីការប្រាក់ និងចំណាយលើការប្រាក់ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ វិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព គឺជាវិធីសាស្ត្រនៃការគណនារំលស់ថ្លៃដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ និងបែងចែកចំណូលពីការប្រាក់ ឬចំណាយលើការប្រាក់ទៅតាមរយៈពេលដែលពាក់ព័ន្ធ។ អត្រាការប្រាក់ប្រសិទ្ធភាព គឺជាអត្រាដែលអាចធ្វើអប្បហារសាច់ប្រាក់ដែលរំពឹងថានឹងទូទាត់ ឬនឹងត្រូវទទួលនាពេលអនាគត តាមរយៈអាយុកាលរំពឹងទុករបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ (ឬរយៈពេលខ្លីជាងប្រសិនបើសមស្រប) ទៅតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុនោះ។

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាព ក្រុមហ៊ុនធ្វើការប៉ាន់ស្មានលើលំហូរទឹកប្រាក់នាពេលអនាគត ដោយពិចារណារាល់លក្ខខណ្ឌទាំងអស់របស់កិច្ចសន្យាឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនរាប់បញ្ចូលនូវការខាតបង់ឥណទានរំពឹងទុកនាពេលអនាគតនោះទេ។

ការគណនាអត្រាការប្រាក់ប្រសិទ្ធភាព រួមបញ្ចូលនូវថ្លៃដើមប្រតិបត្តិការ និងកម្រៃទាំងអស់ដែលបានបង់ ឬបានទទួល ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព។ ថ្លៃដើមប្រតិបត្តិការរួមមាន ការចំណាយបន្ថែមដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការទិញ ឬការបោះផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

## ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

### កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
### សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022

### 27. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ថ. កម្រៃ និងជើងសា

ចំណូល និងចំណាយកម្រៃ និងជើងសា ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាពរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានរួមបញ្ចូលទៅក្នុងការវាស់វែងនៃអត្រាការប្រាក់ប្រសិទ្ធភាព។

ចំណូលកម្រៃ និងជើងសាផ្សេងទៀត ត្រូវបានទទួលស្គាល់នៅពេលបានបំពេញសេវាកម្មពាក់ព័ន្ធ។ ប្រសិនបើការសន្យាផ្តល់ឥណទានមិន ត្រូវបានរំពឹងថានឹងមានលទ្ធផលក្នុងការដកប្រាក់ នោះកម្រៃពីការសន្យាផ្តល់ឥណទានពាក់ព័ន្ធ ត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានរំលស់ថេរទៅតាមថេរវេលានៃកិច្ចសន្យា។

ចំណាយកម្រៃ និងជើងសាផ្សេងៗ ពាក់ព័ន្ធជាចម្បងលើកម្រៃប្រតិបត្តិការ និងសេវាកម្ម ត្រូវបានចំណាយនៅពេលសេវាកម្មត្រូវបានទទួល។

### ទ. ភតិសន្យា

ភតិសន្យា ត្រូវបានចាត់ថ្នាក់ជាភតិសន្យាហិរញ្ញវត្ថុ នៅពេលដែលលក្ខខណ្ឌនៃភតិសន្យា ផ្ទេររាល់ហានិភ័យ និងអត្ថប្រយោជន៍នៃភាពជាកម្មសិទ្ធិនៃទ្រព្យសកម្មដែលបានជួលទាំងអស់ឲ្យស្ថិតនៅក្រោមក្រុមហ៊ុន។ ភតិសន្យាផ្សេងៗទៀត គឺត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិការ។

ការទូទាត់ភតិសន្យាដែលធ្វើឡើងក្រោមភតិសន្យាប្រតិបត្តិការ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាតតាមមូលដ្ឋានរំលស់ថេរទៅតាមរយៈពេលនៃការជួល។ ប្រាក់លើកទឹកចិត្តភតិសន្យាដែលបានទទួល ត្រូវបានទទួលស្គាល់ថាជាផ្នែកមួយនៃចំណាយភតិសន្យាសរុបក្នុងរយៈពេលនៃការជួល។

### ធ. ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញ រួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ។ វាត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត លើកលែងតែធាតុណាបានទទួលស្គាល់ដោយផ្ទាល់ក្នុងមូលធន ឬនៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ។

#### *(i). ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ*

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ គឺជាពន្ធដែលរំពឹងថាត្រូវទូទាត់ ឬត្រូវទទួលលើប្រាក់ចំណេញ ឬខាតជាប់ពន្ធប្រចាំឆ្នាំ និងនិយ័តភាពលើពន្ធដែលត្រូវទូទាត់ ឬត្រូវទទួលដែលទាក់ទងទៅនឹងការិយបរិច្ឆេទមុនៗ។ ចំនួននៃពន្ធដែលត្រូវទូទាត់ ឬត្រូវទទួលប្រចាំឆ្នាំ គឺជាការប៉ាន់ស្មានដ៏ល្អបំផុតនៃចំនួនពន្ធដែលរំពឹងថានឹងត្រូវទូទាត់ ឬត្រូវទទួល ដែលឆ្លុះបញ្ចាំងពីភាពមិនច្បាស់លាស់ទាក់ទងនឹងពន្ធលើប្រាក់ចំណេញ ប្រសិនបើមាន។ វាត្រូវបានវាស់វែងដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទរាយការណ៍។

## 27. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### ធ. ពន្ធលើប្រាក់ចំណេញ (ត)

*(ii). ពន្ធពន្យារ*

ពន្ធពន្យារ ត្រូវបានទទួលស្គាល់លើភាពខុសគ្នាបណ្តោះអាសន្នរវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុល ក្នុងគោលបំណងនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងប្រើសម្រាប់ការគិតពន្ធ។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់សម្រាប់ការខាតពន្ធមិនបានប្រើប្រាស់ ឥណទានពន្ធមិនបានប្រើប្រាស់ និងភាពលម្អៀងជាបណ្តោះអាសន្នដែលអាចកាត់កងបាន តែក្នុងករណីអាចនឹងកើតមានឡើងលើប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតដែលអាចប្រើប្រាស់បាន។ ប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត ត្រូវបានកំណត់ដោយផ្អែកលើផែនការអាជីវកម្មរបស់ក្រុមហ៊ុន និងភាពខុសគ្នាបណ្តោះអាសន្នពីចំនួនដែលទទួលបានមកវិញ។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យនៅរាល់កាលបរិច្ឆេទរាយការណ៍ ហើយត្រូវបានកាត់បន្ថយក្នុងករណីដែលវាមិនអាចកើតឡើងនូវអត្ថប្រយោជន៍ពន្ធដែលពាក់ព័ន្ធ ដែលអាចនឹងប្រើប្រាស់បាន។

ពន្ធពន្យារជាទ្រព្យសកម្មដែលមិនបានទទួលស្គាល់ ត្រូវបានវាយតម្លៃឡើងវិញនៅកាលបរិច្ឆេទរាយការណ៍នីមួយៗ និងត្រូវបានទទួលស្គាល់តែក្នុងករណីដែលអាចនឹងកើតមានឡើងនូវអត្ថប្រយោជន៍ជាប់ពន្ធនាពេលអនាគតដែលអាចប្រើប្រាស់បាន។

ពន្ធពន្យារ ត្រូវបានកំណត់ដោយប្រើអត្រាពន្ធដែលរំពឹងថានឹងប្រើលើភាពខុសគ្នាបណ្តោះអាសន្ននៅពេលមានការកែប្រែ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទរាយការណ៍។

ការវាស់វែងពន្ធពន្យារឆ្លុះបញ្ចាំងពីលទ្ធផល ដែលក្រុមហ៊ុនរំពឹងថា (នៅកាលបរិច្ឆេទរាយការណ៍) នឹងទទួលបានមកវិញ ឬការកាត់កងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុល។

ពន្ធពន្យារជាទ្រព្យសកម្ម និងពន្ធពន្យារជាបំណុល ត្រូវបានកាត់កង នៅពេលដែលក្រុមហ៊ុនមានសិទ្ធិស្របច្បាប់ដើម្បីកាត់កងបំណុល និងទ្រព្យសកម្មពន្ធប្រចាំឆ្នាំ ហើយពន្ធពន្យារនោះមានការទាក់ទងទៅនឹងពន្ធលើប្រាក់ចំណេញដែលបានកំណត់ដោយអាជ្ញាធរពន្ធដារតែមួយ ឬផ្សេងៗគ្នា ប៉ុន្តែគេមានបំណងចង់ទូទាត់វាតាមមូលដ្ឋានកាត់កង ឬមានបំណងទទួលស្គាល់ទ្រព្យសកម្ម និងបំណុលពន្ធទាំងនោះក្នុងពេលដំណាលគ្នា។